រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

# ប្លង់មេរៀន

# ការលើកកម្ពស់សុខភាពសហគមន៍

354.968
HEA-COM

ខែកក្កដា ឆ្នាំ២០០៦

NCDD Library
000412

sh: training

# មាតិកាអត្ថបទ


| | | |
|---|---|---|
| កិច្ចចាប់ផ្តើមនៃវគ្គបណ្តុះបណ្តាល | | ១ |
| កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល | | ៥ |
| ប្លង់មេរៀនទី១ | : ការធ្វើឱ្យប្រសើរនូវស្ថានភាពសុខភាពដើម្បីឱ្យកុមាររស់រានមានជីវិត និងលូតលាស់ល្អ | ៦ |
| ប្លង់មេរៀនទី២ | : តួនាទី និងភារកិច្ចអាជ្ញាធរមូលដ្ឋាន ភ្នាក់ងារសេវាសុខភាពសហគមន៍ និងមណ្ឌលសុខភាព | ១៣ |
| ប្លង់មេរៀនទី៣ | : ការពិនិត្យផ្ទៃពោះមុនពេលសម្រាល | ១៥ |
| ប្លង់មេរៀនទី៤ | : ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ និងការផ្តល់អាហារបន្ថែម | ២០ |
| ប្លង់មេរៀនទី៥ | : ថ្នាំបង្ការជំងឺ និងអាហារូបត្ថម្ភ | ២២ |
| ប្លង់មេរៀនទី៦ | : ជំងឺរាក | ២៧ |
| ប្លង់មេរៀនទី៧ | : ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម | ៣១ |
| ប្លង់មេរៀនទី៨ | : មេរោគអេដស៍ ឬជំងឺអេដស៍ | ៣៧ |
| ប្លង់មេរៀនទី៩ | : ជំងឺផ្តាសាយបក្សី | ៤៤ |
| ប្លង់មេរៀនទី១០ | : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន | ៤៨ |

# កិច្ចចាប់ផ្តើមនៃវគ្គបណ្តុះបណ្តាល

មុននឹងចូលដល់មេរៀនទីមួយ អ្នកសម្របសម្រួលអនុវត្តសកម្មភាពមួយចំនួនខាងក្រោម ÷

- ការណែនាំឱ្យស្គាល់គ្នា
- គោលបំណងនៃវគ្គបណ្តុះបណ្តាល
- វិន័យសម្រាប់វគ្គបណ្តុះបណ្តាល
- សិក្ខាកាមដែលចូលរួមវគ្គបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់
- កម្មវិធីបណ្តុះបណ្តាល
- ការណែនាំអំពីរបៀបបំពេញទម្រង់វាយតម្លៃវគ្គបណ្តុះបណ្តាល

## ១). **ការណែនាំឱ្យស្គាល់គ្នា** (ប្រហែល១០នាទី)

អ្នកសម្របសម្រួលអាចប្រើប្រាស់វិធីសាស្ត្រផ្សេងៗ ក្នុងការណែនាំឱ្យស្គាល់គ្នា ដើម្បីឱ្យស្គាល់ឈ្មោះ តួនាទី ទីកន្លែងធ្វើការងារ ឬកន្លែងរស់នៅ ចំណង់ចំណូលចិត្ត . . . ។ល ។

## ២). **គោលបំណងនៃវគ្គបណ្តុះបណ្តាល** (ប្រហែល៣នាទី)

អ្នកសម្របសម្រួលជម្រាបគោលបំណងនៃវគ្គបណ្តុះបណ្តាលដល់សិក្ខាកាម ។ នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមនឹង ÷

១. កំណត់បានអំពីសារៈសំខាន់ និងមូលហេតុនៃបញ្ហាសុខភាពនៅក្នុងឃុំ សង្កាត់របស់ខ្លួន

២. កំណត់បានអំពីសេវាសុខភាពដែលមាននៅក្នុងឃុំ សង្កាត់របស់ខ្លួន ដើម្បីដោះស្រាយបញ្ហាសុខភាព

៣. បង្កើតផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាសុខភាពទាំងនេះ ។

## ៣). **វិន័យសម្រាប់វគ្គបណ្តុះបណ្តាល** (ប្រហែល៥នាទី)

អ្នកសម្របសម្រួលរួមជាមួយសិក្ខាកាម កំណត់វិន័យសម្រាប់វគ្គបណ្តុះបណ្តាល ។

## ៤). **សិក្ខាកាមនៅថ្នាក់ឃុំ សង្កាត់** (ប្រហែល៥នាទី)

ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ ក្នុងមួយវគ្គៗ មានសិក្ខាកាមចូលរួមពី២៥ ទៅ ៣០នាក់ ។ ឃុំ សង្កាត់នីមួយៗ មានចំនួនសិក្ខាកាម៨នាក់ ក្នុងនោះរួមមាន ÷

- មេឃុំ ចៅសង្កាត់
- ជំទប់ទី២ ចៅសង្កាត់រងទី២
- អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ

- មេភូមិ១នាក់
- ប្រធានមណ្ឌលសុខភាព
- ពេទ្យឆ្មបនៃមណ្ឌលសុខភាព១នាក់ និង
- ភ្នាក់ងារសេវាសុខភាពសហគមន៍២នាក់។

ក្នុងករណីមណ្ឌលសុខភាពបម្រើឱ្យឃុំ សង្កាត់លើសពីមួយ ឃុំ សង្កាត់ដែលមណ្ឌលសុខភាពតាំងនៅ ជាអ្នកអញ្ជើញប្រធានមណ្ឌលសុខភាព ហើយឃុំ សង្កាត់ដែលមណ្ឌលសុខភាពមិនតាំងនៅ ជាអ្នកអញ្ជើញពេទ្យឆ្មបមណ្ឌលសុខភាព។ ចំនួនកន្លែងដែលនៅទំនេរ ឃុំ សង្កាត់ត្រូវអញ្ជើញភ្នាក់ងារសេវាសុខភាពសហគមន៍ ដើម្បីឱ្យបានគ្រប់ចំនួន៨នាក់ ក្នុងមួយឃុំ សង្កាត់។

## ៥). **កម្មវិធីបណ្ដុះបណ្ដាល** (ប្រហែល៥នាទី)

អ្នកសម្របសម្រួលជម្រាបដល់សិក្ខាកាមអំពីកម្មវិធីបណ្ដុះបណ្ដាល។

| ពេលវេលា | ប្រធានបទ | អ្នកសម្របសម្រួល |
|---|---|---|
| | ថ្ងៃទី១ | |
| 07:30-08:00 | ការមកដល់របស់សិក្ខាកាម និងភ្ញៀវ | |
| 08:00-08:30 | កិច្ចចាប់ផ្ដើមនៃវគ្គបណ្ដុះបណ្ដាល | |
| 08:30-10:00 | មេរៀនទី១ : ការធ្វើឱ្យប្រសើរនូវស្ថានភាពសុខភាព ដើម្បីឱ្យកុមាររស់រានមានជីវិត និងលូតលាស់ល្អ | |
| 10:00-10:15 | សម្រាកអាហារសម្រន់ តែ កាហ្វេ | |
| 10:15-11:30 | មេរៀនទី២ : តួនាទី និងភារកិច្ចរបស់អាជ្ញាធរមូលដ្ឋាន ភ្នាក់ងារសេវាសុខភាពសហគមន៍ និងមណ្ឌលសុខភាព | |
| 11:30-14:00 | សម្រាកអាហារថ្ងៃត្រង់ | |
| 14:00-15:00 | មេរៀនទី៣ : ការពិនិត្យផ្ទៃពោះមុនពេលសម្រាល | |
| 15:00-15:30 | មេរៀនទី៤ : ការបំបៅកូនដោយទឹកដោះម្ដាយតែមួយមុខគត់ និងការផ្ដល់អាហារបន្ថែម | |
| 15:30-15:45 | សម្រាកអាហារសម្រន់ តែ កាហ្វេ | |
| 15:45-17:30 | មេរៀនទី៥ : ថ្នាំបង្ការជំងឺ និងអាហារូបត្ថម្ភ | |

| ថ្ងៃទី២ | | |
|---|---|---|
| 08:00-09:00 | មេរៀនទី៦ : ជំងឺរាក | |
| 09:00-10:00 | មេរៀនទី៧ : ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម | |
| 10:00-10:15 | សម្រាកអាហារសម្រន់ តែ កាហ្វេ | |
| 10:15-11:30 | មេរៀនទី៨ : មេរោគអេដស៍ ឬជំងឺអេដស៍ | |
| 11:30-14:00 | សម្រាកអាហារថ្ងៃត្រង់ | |
| 14:00-14:45 | មេរៀនទី៩ : ជំងឺគ្រុនផ្តាសាយបក្សី | |
| 14:45-15:00 | សម្រាកអាហារសម្រន់ តែ កាហ្វេ | |
| 15:00-17:30 | មេរៀនទី១០ : ការបូកសរុបផែនការសកម្មភាព | |

## ៦). ការណែនាំអំពីរបៀបបំពេញទម្រង់វាយតម្លៃវគ្គបណ្តុះបណ្តាល (ប្រហែល១០នាទី)

អ្នកសម្របសម្រួលត្រូវពន្យល់អំពីរបៀបបំពេញទម្រង់វាយតម្លៃ និងរំលឹកដល់សិក្ខាកាមឱ្យបំពេញទម្រង់វាយតម្លៃបន្ទាប់ពីបញ្ចប់មេរៀននីមួយៗ។

# ការវាយតម្លៃវគ្គបណ្តុះបណ្តាលស្តីពីការលើកកម្ពស់សុខភាពសហគមន៍
## (Training Evaluation on Communinty Health Improvement)

| | ខ្លឹមសារមេរៀន Content | | | | | | | | | | ការសម្របសម្រួល Facilitation | | | | | | | | | | លំហាត់ និងការអនុវត្តជាក់ស្តែង Exercise | | | | | | | | | | ពេលវេលា Time | | | | | | | | | | កម្រិតយល់ដឹងរបស់សិក្ខាកាម Level of Understanding | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| មេរៀន | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| Lesson | អន់ (Bad) | | | | | | | | | ល្អ (Good) | អន់ (Bad) | | | | | | | | | ល្អ (Good) | អន់ (Bad) | | | | | | | | | ល្អ (Good) | អន់ (Bad) | | | | | | | | | ល្អ (Good) | អន់ (Bad) | | | | | | | | | ល្អ (Good) |
| 1 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 2 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 3 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 4 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 5 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 6 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 7 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 8 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 9 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 10 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

មតិយោបល់ផ្សេងៗ (Other Comments)

# កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

១). អ្នកសម្របសម្រួល និងអ្នកគាំទ្រផ្នែកបច្ចេកទេស

ឯកសារបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងសម្រាប់អ្នកដែលមានជំនាញសម្របសម្រួល និងធ្លាប់ពាក់ព័ន្ធនឹងបញ្ហានារីនិងកុមារ និងវិមជ្ឈការនៅក្នុងប្រទេសកម្ពុជា ដើម្បីបណ្តុះបណ្តាលបន្តដល់ថ្នាក់ឃុំ សង្កាត់។

អ្នកគាំទ្រផ្នែកបច្ចេកទេស គឺតំណាងមកពីមន្ទីរសុខាភិបាលខេត្ត ក្រុង ឬ និងការិយាល័យស្រុកប្រតិបត្តិ។

២). តួនាទីរបស់អ្នកសម្របសម្រួល និងអ្នកគាំទ្រផ្នែកបច្ចេកទេស

អ្នកសម្របសម្រួល និងអ្នកគាំទ្រផ្នែកបច្ចេកទេស នឹងបំពេញតួនាទីខុសៗគ្នា ប៉ុន្តែបំពេញឱ្យគ្នាទៅវិញទៅមក ដើម្បីធ្វើឱ្យសិក្ខាកាមរៀនសូត្រប្រកបដោយប្រសិទ្ធភាព។ ជាប្រការមួយសំខាន់ ដែលអ្នកសម្របសម្រួលធ្វើការពិភាក្សាជាមួយអ្នកគាំទ្រផ្នែកបច្ចេកទេស មុននឹងដំណើរការវគ្គបណ្តុះបណ្តាល ដើម្បីបែងចែកការងារ និងមេរៀនដែលត្រូវសម្របសម្រួល។

ប្លង់មេរៀននេះត្រូវបានធ្វើការបណ្តុះបណ្តាលសាកល្បង និងកែសម្រួលជាច្រើនសារ ហេតុដូចនេះ អ្នកសម្របសម្រួល ត្រូវអនុវត្តតាមការណែនាំនៅក្នុងប្លង់មេរៀននេះជាចាំបាច់។ ប្រសិនបើអ្នកសម្របសម្រួលគ្រប់គ្រងពេលវេលាបានល្អ នោះការបណ្តុះបណ្តាល នឹងដំណើរការបានយ៉ាងរលូន ហើយបញ្ចប់តាមការគ្រោងទុក។

## ក). អ្នកសម្របសម្រួល

អ្នកសម្របសម្រួល មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- ត្រៀមរៀបចំឯកសារ និងសម្ភារសម្រាប់ការបណ្តុះបណ្តាល
- គោរព និងអនុវត្តតាមសកម្មភាពដែលបានពិពណ៌នា នៅក្នុងប្លង់មេរៀន
- សម្របសម្រួលការពិភាក្សាជាក្រុម

## ខ). អ្នកគាំទ្រផ្នែកបច្ចេកទេស

អ្នកគាំទ្រផ្នែកបច្ចេកទេស មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- សហការជាមួយអ្នកសម្របសម្រួល ក្នុងការបញ្ជាក់បន្ថែមលើខ្លឹមសារបច្ចេកទេស បើចាំបាច់
- សហការជាមួយអ្នកសម្របសម្រួល ក្នុងការសម្របសម្រួលដំណើរការវគ្គបណ្តុះបណ្តាល
- សម្របសម្រួលមេរៀនមួយចំនួន ឬផ្នែកមួយចំនួននៃមេរៀន ទៅតាមការពិភាក្សា និងឯកភាពជាមួយអ្នកសម្របសម្រួល
- សហការជាមួយអ្នកសម្របសម្រួល ក្នុងការសម្របសម្រួលក្រុមពិភាក្សា
- សង្កេតសកម្មភាពបណ្តុះបណ្តាល និងផ្តល់យោបល់ដល់អ្នកសម្របសម្រួល នៅពេលបញ្ចប់មេរៀននីមួយៗ

# ប្លង់មេរៀនទី១
# ការធ្វើឱ្យប្រសើរនូវស្ថានភាពសុខភាព
# ដើម្បីឱ្យកុមាររស់រានមានជីវិត និងលូតលាស់ល្អ

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង :<br>• យល់ច្បាស់អំពីអត្ថប្រយោជន៍នៃសុខភាពល្អចំពោះការអភិវឌ្ឍទូទៅ នៅក្នុងភូមិរបស់ពួកគេទាំងមូល<br>• ដឹងច្បាស់អំពីសេវាសុខភាពគ្រប់លំដាប់ថ្នាក់ដែលមានសម្រាប់ប្រជាពលរដ្ឋ<br>• ប្តេជ្ញាធ្វើការកែលម្អស្ថានភាពសុខភាព ហើយចាត់ទុកកិច្ចការនេះ ជាអាទិភាពរបស់ឃុំ សង្កាត់។ |
| រយៈពេលសរុប | ប្រហែល ៩០នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កន្រ្តៃ និងឯកសារលំហាត់១.១. ១.២. ១.៣។ |
| វិធីសាស្រ្ត | ការបំផុសគំនិត ការបង្ហាញ និងការពិភាក្សាតាមក្រុម។ |

សកម្មភាពសម្របសម្រួលមេរៀន :

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | ១. ការបំផុសសំណួរ<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយសួរសិក្ខាកាមថា "តើអាចធ្វើអ្វីបានខ្លះ ដើម្បីការពារកុមារក្នុងឃុំ សង្កាត់របស់អ្នក កុំឱ្យឆ្លងជំងឺ និងដើម្បីប្រាកដថាពួកគេលូតលាស់បានល្អ?"។ រាល់ចម្លើយត្រូវកត់ត្រានៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ ក្នុងករណីសិក្ខាកាមមិនអាចផ្តល់ចម្លើយបាន អ្នកសម្របសម្រួលត្រូវបំផុសសំណួរបន្ត។<br>ចម្លើយអាចមាន :<br>• ម្តាយមានសុខភាពមាំមួន<br>• បរិស្ថានជុំវិញស្អាត និងមានអនាម័យ<br>• ទឹកស្អាត និងបង្គន់អនាម័យ<br>• ទទួលថ្នាំបង្ការ<br>• បំបៅកូនអាយុក្រោម៦ខែដោយទឹកដោះម្តាយតែមួយមុខគត់<br>• ផ្តល់អាហារូបត្ថម្ភ (អាហារល្អ ទ្រទ្រង់សុខភាព និងគ្រប់គ្រាន់)<br>• មណ្ឌលសុខភាពល្អ និងមានដំណើរការ<br>• ប្រើអំបិលអ៊ីយ៉ូដ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១០នាទី | **២. ការបំផុសសំណួរ និងការបង្ហាញខ្លឹមសារ**<br>អ្នកសម្របសម្រួលបន្តដោយសួរសំណួរថា ៖<br>• តើអ្នក ឬសមាជិកក្នុងគ្រួសាររបស់អ្នកធ្លាប់មានជំងឺដែរឬទេ?<br>• តើគ្រួសារអ្នកត្រូវចំណាយប្រាក់អស់ប្រហែលប៉ុន្មានទៅលើការថែទាំសុខភាព ក្នុងមួយឆ្នាំៗ?<br>អ្នកសម្របសម្រួលកត់ត្រាចំនួនតួលេខប៉ាន់ស្មានចំណាយរបស់សិក្ខាកាម។ បន្ទាប់មកអ្នកសម្របសម្រួលបង្ហាញខ្លឹមសារខាងក្រោមនេះ ៖<br>"ប្រជាពលរដ្ឋកម្ពុជាម្នាក់ ត្រូវចំណាយអស់ប្រាក់ចំនួន៨០.០០០រៀល ទៅលើការថែទាំសុខភាពក្នុងមួយឆ្នាំៗ។ បើក្នុងគ្រួសាររបស់អ្នកមានសមាជិក៥នាក់ មានន័យថាគ្រួសាររបស់អ្នក ត្រូវចំណាយ ៤០០.០០០រៀលក្នុងមួយឆ្នាំ និង ២.០០០.០០០រៀល ក្នុងរយៈពេល៥ឆ្នាំ នេះជាការចំណាយដ៏ច្រើនលើសលប់" (ការអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០០០)។ | |
| ១២នាទី | **៣. លំហាត់ ១.១ ៖ ការចំណាយតាមគ្រួសារទៅលើការថែទាំសុខភាព**<br>អ្នកសម្របសម្រួលចែកឯកសារលំហាត់ ១.១.ការចំណាយតាមគ្រួសារទៅលើការថែទាំសុខភាព ហើយអញ្ជើញសិក្ខាកាមម្នាក់អាន។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់សិក្ខាកាមអំពីរបៀបបំពេញចម្លើយ ហើយទុកពេលឱ្យសិក្ខាកាមបំពេញរៀងៗខ្លួនៗ។ អ្នកសម្របសម្រួលត្រូវប្រាប់ថា សិក្ខាកាមម្នាក់ៗអាចបំពេញចម្លើយបាន។ | ឯកសារលំហាត់១.១ |
| ១៣នាទី | **៤. ការបំផុសសំណួរ**<br>អ្នកសម្របសម្រួលបំផុសសំណួរ តើត្រូវចំណាយទៅលើអ្វីខ្លះ ឬខាតបង់អ្វីខ្លះក្នុងពេលឈឺ?។ កត់ត្រាចម្លើយរបស់សិក្ខាកាមនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។<br>**ចម្លើយអាចមាន ៖**<br>• ចំណាយលើថ្នាំព្យាបាល<br>• ចំណាយលើសេវាព្យាបាល<br>• ចំណាយលើការដឹកអ្នកជំងឺ<br>• ខាតពេលវេលាធ្វើការងារ និងរកស៊ី<br>• ...។ល។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | អ្នកសម្របសម្រួលបន្តបំផុសសំណួរ តើកុមារភាគច្រើនតែងជួបប្រទះជំងឺអ្វីខ្លះ? កត់ត្រាចម្លើយរបស់សិក្ខាកាមនៅលើក្ដារខៀន ឬក្រដាសផ្ទាំងធំ។<br>**ចម្លើយអាចមាន :**<br>• ជំងឺរាគ<br>• ជំងឺគ្រុនឈាម<br>• ក្ដៅខ្លួន ឬគ្រុនផ្ដាសាយ<br>• ជំងឺរលាកទងសួត<br>• ជំងឺរលាកបំពង់ក<br>• . . .។ល។<br>អ្នកសម្របសម្រួលបញ្ចប់សកម្មភាពនេះដោយបញ្ជាក់ដល់សិក្ខាកាមថា "ជំងឺមួយចំនួនអាចការពារបាន ហើយជំងឺមួយចំនួនចំណាយតែបន្តិចបន្តួចប៉ុណ្ណោះ បើធ្វើការព្យាបាលទាន់ពេលវេលា (ពីដំបូង) និងនៅកន្លែងផ្ដល់សេវាសុខភាពត្រឹមត្រូវ"។ | |
| ១០នាទី | ៥. ការបញ្ជាក់ និងបំផុសសំណួរ<br>អ្នកសម្របសម្រួលបញ្ជាក់ដល់សិក្ខាកាមថា ផ្អែកតាមសៀវភៅស្ថានភាពកុមារពិភពលោកឆ្នាំ២០០៤ "នៅក្នុងឆ្នាំ២០០២ មានកុមារកម្ពុជាចំនួនប្រហែល ៦៥.០០០នាក់ បានស្លាប់មុនអាយុ៥ឆ្នាំ" បន្ទាប់មកបំផុសសំណួរថា "តើយើងអាចបង្ការមរណភាពរបស់កុមារបានដែរឬទេ?" ហើយឆ្លើយថា យើងអាចបង្ការមរណភាពរបស់កុមារបាន។<br><br>អ្នកសម្របសម្រួលជម្រាបដល់សិក្ខាកាមថា "នៅក្នុងវគ្គបណ្ដុះបណ្ដាលនេះ យើងចង់ឱ្យសិក្ខាកាមគិតអំពីអ្វីដែលពួកគេអាចធ្វើបាន ក្នុងនាមជាសហគមន៍ និងអ្នកដឹកនាំសហគមន៍ ដើម្បីការពារកូនៗរបស់អ្នកឱ្យជៀសផុតពីមរណភាពទាំងនេះ និងវិធីដែលធ្វើឱ្យកុមាររស់នៅប្រកបដោយសុខភាពល្អបរិបូណ៌។ កិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរមូលដ្ឋាន មណ្ឌលសុខភាព និងភ្នាក់ងារសេវាសុខភាពសហគមន៍ គឺជាការចាំបាច់ក្នុងការជួយដល់កិច្ចការនេះ។ តាមរយៈការអនុវត្តសកម្មភាពទាំងនេះ អ្នក និងគ្រួសាររបស់អ្នកអាចកាត់បន្ថយនូវការចំណាយដ៏ច្រើនលើសលប់ទៅលើសុខភាព ហើយរស់នៅប្រកបដោយសុខភាពមាំមួន"។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១០នាទី | ៦. ការបំផុសសំណួរ<br>អ្នកសម្របសម្រួលបន្តដោយលើកឡើងថា "យើងបានដឹងហើយថា ការថែទាំសុខភាព គឺសំខាន់ណាស់ដែលអាចធ្វើឱ្យកុមាររស់រានមានជីវិត និងលូតលាស់បានល្អប្រសើរ និងធ្វើឱ្យយើងសន្សំប្រាក់បានច្រើន" ហើយចោទសំណួរថា តើនៅក្នុងសហគមន៍របស់អ្នកមានកន្លែងសេវាសុខភាពអ្វីខ្លះ? តើអ្នកអាចធ្វើដូចម្តេច ដើម្បីឱ្យសេវាសុខភាពទាំងនោះកាន់តែប្រសើរឡើង?។ រាល់ចម្លើយរបស់សិក្ខាកាមត្រូវកត់ត្រានៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ ។<br>ចម្លើយអាចមាន : (តើនៅក្នុងសហគមន៍របស់អ្នកមានសេវាសុខភាពអ្វីខ្លះ?)<br>• ប៉ុស្តិ៍សុខភាព<br>• មណ្ឌលសុខភាព<br>• មន្ទីរពេទ្យបង្អែក<br>• ការផ្តល់សេវាចុះមូលដ្ឋាន<br>ចម្លើយអាចមាន : (តើអ្នកអាចធ្វើដូចម្តេច ដើម្បីឱ្យសេវាសុខភាពទាំងនោះកាន់តែប្រសើរឡើង?)<br>• ចូលរួមក្នុងការកសាងផែនការមណ្ឌលសុខភាព<br>• ពង្រឹងគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព<br>• បញ្ចូលសកម្មភាពអប់រំសុខភាពទៅក្នុងកម្មវិធីវិនិយោគពាឆ្នាំរំកិលរបស់ឃុំ សង្កាត់<br>• រាយការណ៍អំពីចំណុចខ្សោយ ឬអសកម្មទៅថ្នាក់លើ<br>• ចូលរួមចំណែកផ្ទាល់ដើម្បីកែលម្អចំណុចខ្វះខាត<br>• ធ្វើការតាមដានសកម្មភាពផ្តល់សេវាសុខភាព នៅក្នុងឃុំ សង្កាត់<br>• សហការ និងជំរុញសកម្មភាពសេវាសុខភាព នៅក្នុងឃុំ សង្កាត់ | |
| ២០នាទី | ៧. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ១.១.សកម្មភាពនានានៅតាមសេវាសុខភាពនីមួយៗ និង១.២.ព័ត៌មានសំខាន់ៗអំពីសេវារបស់មណ្ឌលសុខភាព ហើយអញ្ជើញសិក្ខាកាមអានម្តងមួយចំណុចៗ។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ ព្រមទាំងលើកឧទាហរណ៍ ។ | ខ្លឹមសារមេរៀន ១.១ និង ១.២ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១៥នាទី | ៩. ការបង្ហាញ និងការបំពេញតារាងតម្លៃសេវាសុខភាព<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ១.៣.ការបង់ថ្លៃសេវាសុខភាព ហើយអញ្ជើញសិក្ខាកាមអានម្តងមួយចំណុចៗ។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ ព្រមទាំងលើកឧទាហរណ៍។<br>អ្នកសម្របសម្រួលចែក "តារាងតម្លៃសេវាសុខភាព" ដល់សិក្ខាកាមគ្រប់ៗគ្នា។ បន្ទាប់មកអ្នកសម្របសម្រួលអញ្ជើញមន្ត្រីសុខាភិបាល ដែលជាអ្នកជំនួយផ្នែកបច្ចេកទេស (ឬអ្នកសម្របសម្រួលខ្លួនឯង បើអាចធ្វើបាន) ជម្រាបសិក្ខាកាមអំពីថ្លៃសេវាសុខភាព នៅក្នុងតំបន់នោះ ហើយស្នើសុំឱ្យសិក្ខាកាមកត់ត្រាតម្លៃសេវាសុខភាពទាំងនោះ ចូលទៅក្នុងទម្រង់ថ្លៃសេវាសុខភាពដែលបានចែកជូន។ | -ខ្លឹមសារមេរៀន ១.៣<br>-ទម្រង់ថ្លៃសេវាសុខភាព |
| ៥នាទី | ១០. ការបង្ហាញ និងធ្វើសុពលភាព<br>អ្នកសម្របសម្រួលចែកឯកសារលំហាត់ ១.២.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមទៅក្នុងឯកសារលំហាត់១.២ នូវសកម្មភាពដែលបានបន្ថែមទាំងនោះ។ | ឯកសារលំហាត់១.២ |

## ឯកសារលំហាត់ ១.១ : ការចំណាយតាមគ្រួសារទៅលើការថែទាំសុខភាព

នៅប្រទេសកម្ពុជាក្នុង១ឆ្នាំៗ ប្រជាជនកម្ពុជាម្នាក់ចំណាយ ៨០.០០០រៀល ទៅលើការថែទាំសុខភាព។ ប្រសិនក្នុងគ្រួសារមានសមាជិក..........នាក់ តើក្នុង១ឆ្នាំគ្រួសារអ្នកត្រូវចំណាយប៉ុន្មាន?

ប្រសិនបើយើងរស់នៅប្រកបដោយសុខភាពល្អ យើងអាចសន្សំបាន........................................ក្នុង១ឆ្នាំ យើងអាចសន្សំបាន.................................. ក្នុងរយៈពេល៥ឆ្នាំ និង.................................. ក្នុងរយៈពេល១០ឆ្នាំ។

ទោះបីជាគ្រួសារនីមួយៗ ត្រូវចំណាយថវិកាច្រើនសម្រាប់ព្យាបាលក៏ដោយ ក៏ជារៀងរាល់ឆ្នាំកុមារកម្ពុជាចំនួន ៦៥.០០០នាក់ បានស្លាប់នៅមុនអាយុ៥ឆ្នាំ។ (ស្ថិតិឆ្នាំ២០០២)

## តារាងតម្លៃសេវាសុខភាព នៅមណ្ឌលសុខភាព (គិតជារៀល)

| ឈ្មោះមណ្ឌលសុខភាព | ការពិគ្រោះព្យាបាលជំងឺ | ការពិគ្រោះមុនសម្រាល | ការពិគ្រោះក្រោយសម្រាល | ការពន្យារកំណើតស្រោមអនាម័យ | ការដាក់កងស្បូន | ការសម្រាលកូនធម្មតា | ការវះកាត់តូចតាច | ការពិគ្រោះព្យាបាលធ្មេញ | ការចាក់ថ្នាំបង្ការ | ការដឹកអ្នកជំងឺទៅមន្ទីរពេទ្យបង្អែក | ការធ្វើរោគវិនិច្ឆ័យមន្ទីរពិសោធន៍ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

## ឯកសារលំហាត់ ១.២ ៖ ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- ឃុំ សង្កាត់ត្រូវចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំផែនការមណ្ឌលសុខភាព
- ឃុំ សង្កាត់ត្រូវប្រាកដថា អ្នកផ្តល់សេវានៅមណ្ឌលសុខភាព ចូលរួមនៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ ឬកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ នៅជំហានទី១ និងទី៣។
- ឃុំ សង្កាត់ត្រូវចូលរួមក្នុងការអនុវត្តសកម្មភាពសេវារបស់មណ្ឌលសុខភាពតាមរយៈស្ថិតិ ការផ្សព្វផ្សាយ និងគាំទ្រដល់អ្នកស្ម័គ្រចិត្តសុខភាពសហគមន៍
- រាយការណ៍ទៅមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងថ្នាក់លើ
- បញ្ចូលបញ្ហាសុខភាពទៅក្នុងរបៀបវារៈនៃការប្រជុំជាប្រចាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

# ប្លង់មេរៀនទី២
# តួនាទី និងភារកិច្ចរបស់អាជ្ញាធរមូលដ្ឋាន
# ភ្នាក់ងារសេវាសុខភាពសហគមន៍ និងមណ្ឌលសុខភាព

| | |
|---|---|
| គោលបំណង | នៅពេលបញ្ចប់មេរៀន សិក្ខាកាមនឹង :<br>• យល់ច្បាស់អំពីតួនាទី និងភារកិច្ចរបស់អាជ្ញាធរមូលដ្ឋាន ភ្នាក់ងារសុខភាពសហគមន៍ និងមណ្ឌលសុខភាព<br>• ដឹងច្បាស់អំពីមធ្យោបាយដែលក្រុមប្រឹក្សាឃុំ សង្កាត់ អាចជួយគាំទ្រដល់ការចូលរួមរបស់សហគមន៍ |
| រយៈពេលសរុប | ប្រហែល ៤៥នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត និងឯកសារលំហាត់២.១។ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការបង្ហាញ និងការពិភាក្សាក្រុមធំ។ |

សកម្មភាពសម្របសម្រួលមេរៀន :

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៣នាទី | **១. ការផ្ដើមសេចក្ដី**<br>អ្នកសម្របសម្រួលចាប់ផ្ដើមដោយលើកឡើងថា "ដូចយើងបានកត់សម្គាល់ក្នុងមេរៀនមុនហើយថា ដើម្បីកែលម្អស្ថានភាពសុខភាពរបស់ស្ត្រី និងកុមារ នៅក្នុងឃុំសង្កាត់របស់យើង មានតួអង្គជាច្រើនចូលរួមពាក់ព័ន្ធ"។ | |
| ៣២នាទី | **២. ការបំផុសសំណួរ និងបង្ហាញខ្លឹមសារមេរៀន**<br>អ្នកសម្របសម្រួលបំផុសសំណួរថា "តើអ្នកណាខ្លះមានតួនាទីយ៉ាងសកម្ម ក្នុងការលើកកម្ពស់ស្ថានភាពសុខភាពរបស់អ្នកភូមិ?"។ រាល់ចម្លើយរបស់សិក្ខាកាមត្រូវកត់ត្រានៅលើក្ដារខៀន ឬក្រដាសផ្ទាំងធំ។ អ្នកសម្របសម្រួលសង្ខេបចម្លើយរបស់សិក្ខាកាមដោយលើកឡើងថា "មានមនុស្សសំខាន់៦ចំនួន៣ក្រុម ដែលមានតួនាទីយ៉ាងសកម្ម ក្នុងការផ្ដល់សេវាសុខភាពដល់ប្រជាពលរដ្ឋ"។<br><br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់មេរៀនទី២ : តួនាទី និងភារកិច្ចអាជ្ញាធរមូលដ្ឋាន ភ្នាក់ងារសេវាសុខភាពសហគមន៍ និងមណ្ឌលសុខភាព ហើយអញ្ជើញសិក្ខាកាមអានម្ដងមួយចំណុច១។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ ព្រមទាំងលើកឧទាហរណ៍។ | ខ្លឹមសារមេរៀនទី២ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | អ្នកសម្របសម្រួលបញ្ចប់សកម្មភាពនេះ ដោយបញ្ជាក់បន្ថែមដល់សិក្ខាកាមថា "អ្នកពាក់ព័ន្ធទាំងអស់ត្រូវដឹងអំពីតួនាទី និងភារកិច្ចរបស់ខ្លួន និងអ្នកដទៃ ហើយត្រូវអនុវត្តតួនាទី និងភារកិច្ចទាំងនោះឱ្យបានត្រឹមត្រូវ និងមានតម្លាភាព"។ | |
| ១០នាទី | ៣. ការបង្ហាញ និងធ្វើសុពលភាព<br>អ្នកសម្របសម្រួលចែកឯកសារលំហាត់ ២.១.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមទៅក្នុងឯកសារលំហាត់២.១ នូវសកម្មភាពដែលបានបន្ថែមទាំងនោះ។ | ឯកសារលំហាត់២.១ |

## ឯកសារលំហាត់ ២.១ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- សម្របសម្រួល និងគាំទ្រការអនុវត្តសកម្មភាពទាក់ទងនឹងសុខភាព។
- រៀបចំរបាយការណ៍អំពីបញ្ហាសុខភាព និងរាយការណ៍ជូនមណ្ឌលសុខភាព ស្រុកប្រតិបត្តិ និងស្ថាប័ន អង្គភាពពាក់ព័ន្ធថ្នាក់លើ។

# ប្លង់មេរៀនទី៣

# ការពិនិត្យផ្ទៃពោះមុនពេលសម្រាល

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង :<br>• យល់ច្បាស់អំពីអត្ថប្រយោជន៍នៃការពិនិត្យផ្ទៃពោះមុនពេលសម្រាល<br>• ដឹងច្បាស់អំពីសកម្មភាពដែលត្រូវអនុវត្តដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងតំណាងភូមិក្នុងការលើកកម្ពស់ការពិនិត្យផ្ទៃពោះមុនពេលសម្រាល នៅក្នុងឃុំ សង្កាត់។ |
| រយៈពេលសរុប | ប្រហែល ៦០នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ក្រដាសទំហំអា៤ និងឯកសារលំហាត់ ៣.១. ៣.២។ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការពិភាក្សាតាមក្រុម សំណួរសរសេរក្រដាសទំហំអា៤។ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៣នាទី | **១. ការផ្តើមសេចក្តី**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា "ជារៀងរាល់ឆ្នាំនៅក្នុងប្រទេសកម្ពុជា មានស្ត្រីកម្ពុជាជាច្រើននាក់ស្លាប់ ដោយសារបញ្ហាផ្សេងៗដែលទាក់ទងនឹងការមានផ្ទៃពោះ និងការសម្រាលកូន។ មានស្ត្រីរាប់ម៉ឺននាក់ទៀត ជួបប្រទះផលវិបាកនៅក្នុងពេលមានផ្ទៃពោះដែលគំរាមកំហែងដល់ជីវិតស្ត្រី និងទារក (ការអង្កេតថ្នាក់ជាតិស្តីពីសុខភាព និងប្រជាសាស្ត្រ ឬសៀវភៅកូនសោសុខភាព)។ ការឈឺ និងស្លាប់ទាំងនេះភាគច្រើនសុទ្ធតែអាចការពារបាន តើអ្នកអាចធ្វើអ្វីខ្លះបាន ក្នុងនាមជាអ្នកដឹកនាំនៅមូលដ្ឋាន?"។ | |
| ២២នាទី | **២. លំហាត់ ៣.១ : ការពិនិត្យផ្ទៃពោះមុនពេលសម្រាល**<br>អ្នកសម្របសម្រួលចែកសិក្ខាកាមជាក្រុមតូចៗ ដែលមានចំនួន៥-៦នាក់ក្នុងមួយក្រុម ហើយបន្ទាប់មកចែកឯកសារលំហាត់ ៣.១.ការពិនិត្យផ្ទៃពោះមុនពេលសម្រាល និងចែកក្រដាសអា៤។ អ្នកសម្របសម្រួលពន្យល់ក្រុមនីមួយៗអំពីរបៀបធ្វើលំហាត់នេះថា : ក្រុមនីមួយៗ គិតពិចារណាឃ្លានីមួយៗ ហើយផ្តល់ចម្លើយ "ខុស" ឬ "ត្រូវ"។ បើអ្នកយល់ថាឃ្លានោះខុស អ្នកត្រូវសរសេរ "ខុស" ផ្ទុយមកវិញបើអ្នកយល់ថាឃ្លានោះត្រូវ អ្នកត្រូវសរសេរ "ត្រូវ" ហើយបិទឱ្យជិតកុំឱ្យក្រុមដទៃមើលឃើញ។ បន្ទាប់មក អ្នកសម្របសម្រួល យកតារាងបូកសរុបពិន្ទុដែលបានរៀបចំរួចជាស្រេចនៅលើក្រដាសផ្ទាំងធំ បិទលើក្តារខៀន ហើយចាប់ផ្តើមធ្វើលំហាត់នេះម្តងមួយៗ។ | -ក្រដាសទំហំអា៤<br>-ឯកសារលំហាត់៣.១ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១០នាទី | ៣. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៣.ការពិនិត្យផ្ទៃពោះមុនពេលសម្រាល ហើយអញ្ជើញសិក្ខាកាមអាន។ នៅពេលបញ្ចប់ការអាន អ្នកសម្របសម្រួលបញ្ជាក់ដល់សិក្ខាកាមថា “យើងមិនពិភាក្សាអំពីមាតុភាពគ្មានគ្រោះថ្នាក់នៅក្នុងវគ្គបណ្តុះបណ្តាលនេះទេ ឯកសារខ្លឹមសារមេរៀនទី៣នេះ ទុកជាចំណេះដឹងបន្ថែម”។<br><br>អ្នកសម្របសម្រួលបញ្ចប់សកម្មភាពនេះដោយបញ្ជាក់បន្ថែមថា “ប្រសិនបើស្ត្រីមានផ្ទៃពោះ បានពិនិត្យផ្ទៃពោះមុនពេលសម្រាល ហើយការសម្រាលកូនប្រកបដោយសុវត្ថិភាពនោះ វាជាការចាប់ផ្តើមមួយដ៏ល្អសម្រាប់ទារក ហើយទារកមានឱកាសដ៏ប្រសើរ ដើម្បីរស់រាន និងការលូតលាស់”។ | ខ្លឹមសារមេរៀនទី៣ |
| ៥នាទី | ៤. ការបំផុសសំណួរ<br>អ្នកសម្របសម្រួលបន្តដោយលើកឡើងថា ឥឡូវនេះយើងដឹងហើយថា ការពិនិត្យផ្ទៃពោះមុនពេលសម្រាលមានសារៈសំខាន់ណាស់ ហើយបំផុសសំណួរថា “តើសេវាពិនិត្យស្ត្រីមានផ្ទៃពោះមាននៅកន្លែងណាខ្លះនៅក្នុងសហគមន៍របស់អ្នក?”។ រាល់ចម្លើយរបស់សិក្ខាកាមត្រូវកត់ត្រានៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។<br>ចម្លើយអាចមាន :<br>• មន្ទីរពេទ្យបង្អែក<br>• មណ្ឌលសុខភាព<br>• ប៉ុស្តិ៍សុខភាព<br>• ការផ្តល់សេវាចុះមូលដ្ឋាន (ចំពោះតំបន់ដាច់ស្រយាល) | |
| ១០នាទី | ៥. ការបំផុសសំណួរ<br>អ្នកសម្របសម្រួលបន្តដោយលើកឡើងថា “ថ្វីត្បិតតែមានសេវានានា ហើយយើងបានដឹងអំពីសារៈសំខាន់នៃការពិនិត្យផ្ទៃពោះមុនពេលសម្រាលក៏ពិតមែន ប៉ុន្តែតើហេតុអ្វីស្ត្រីមានផ្ទៃពោះមិនទៅពិនិត្យផ្ទៃពោះ? តើក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើអ្វីបានខ្លះក្នុងបញ្ហានេះ?។ រាល់ចម្លើយរបស់សិក្ខាកាមត្រូវកត់ត្រានៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១០នាទី | ៦. ការបង្ហាញ និងធ្វើសុពលភាព<br>អ្នកសម្របសម្រួលចែកឯកសារលំហាត់ ៣.២.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែម ទៅក្នុងឯកសារលំហាត់៣.២ នូវសកម្មភាពដែលបានបន្ថែមទាំងនោះ។ | ឯកសារលំហាត់៣.២ |

## ឯកសារលំហាត់ ៣.១ : ការពិនិត្យផ្ទៃពោះមុនពេលសម្រាល

| ល.រ | ការបរិយាយ | ត្រូវ | ខុស |
|---|---|---|---|
| ១ | ស្ត្រីគួរបន្ថយការបរិភោគក្នុងពេលមានផ្ទៃពោះ ដូច្នេះកូនក្នុងផ្ទៃរបស់គេនឹងតូច ហើយងាយស្រួលក្នុងការសម្រាល។ | | |
| ២ | ប្រសិនបើស្ត្រីមានផ្ទៃពោះមានសុខភាពល្អ នោះកូននៅក្នុងផ្ទៃរបស់គេភាគច្រើន នៅពេលកើតមកមានសុខភាពល្អផងដែរ។ | | |
| ៣ | ស្ត្រីត្រូវទៅពិនិត្យផ្ទៃពោះតែនៅពេលមានកូនដំបូងប៉ុណ្ណោះ។ | | |
| ៤ | នៅពេលទៅពិនិត្យសុខភាពក្នុងអំឡុងពេលមានផ្ទៃពោះ ពេទ្យឆ្មបមណ្ឌលសុខភាពនឹងផ្តល់ដំបូន្មានទៅម្តាយពីវិធីថែទាំខ្លួន និងត្រៀមរៀបចំសម្រាប់ការសម្រាលកូន។ | | |
| ៥ | ស្ត្រីមានផ្ទៃពោះត្រូវតែបានចាក់ថ្នាំបង្ការជំងឺតេតាណូសដើម្បីការពារខ្លួននិងទារក ក្នុងអំឡុងពេលសម្រាល។ | | |
| ៦ | ស្ត្រីមានផ្ទៃពោះត្រូវទៅពិនិត្យផ្ទៃពោះតែមួយលើកប៉ុណ្ណោះ នៅមណ្ឌលសុខភាព។ | | |
| ៧ | ស្ត្រីមានផ្ទៃពោះត្រូវទៅពិនិត្យផ្ទៃពោះមុនពេលសម្រាលតែនៅពេលដែលគេមានជំងឺ ឬមានបញ្ហាអ្វីមួយប៉ុណ្ណោះ។ | | |
| ៨ | ស្ត្រីមានផ្ទៃពោះគួរលេបថ្នាំគ្រាប់ជាតិដែកមួយគ្រាប់ក្នុងមួយថ្ងៃ រយៈពេល៩០ថ្ងៃ។ | | |
| ៩ | សញ្ញាគ្រោះថ្នាក់២ដែលបង្ហាញពីស្ត្រីមានផ្ទៃពោះដែលត្រូវតែទៅមណ្ឌលសុខភាព ជាបន្ទាន់ដើម្បីទទួលការព្យាបាល គឺមានហូរឈាមតាមទ្វារមាស ហើមដៃ និងជើងធ្ងន់ធ្ងរ។ | | |
| ១០ | ស្ត្រីមានផ្ទៃពោះ ត្រូវធ្វើតេស្តរកមេរោគអេដស៍ (ការធ្វើតេស្តនេះឥតបង់ថ្លៃទេ)។ | | |

## តារាងបូកសរុបពិន្ទុ

| លេខរៀងឃ្លា | ចម្លើយ | | | | |
|---|---|---|---|---|---|
| | ក្រុមទី១ | ក្រុមទី២ | ក្រុមទី៣ | ក្រុមទី៤ | ក្រុមទី៥ |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |
| ១០ | | | | | |
| សរុបពិន្ទុ | | | | | |

## ឯកសារលំហាត់ ៣.២ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- មេភូមិត្រូវកត់ត្រាចំនួនស្ត្រីមានផ្ទៃពោះនៅក្នុងភូមិរបស់ខ្លួនសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីផ្តល់ព័ត៌មានជូនមណ្ឌលសុខភាពសម្រាប់សកម្មភាពចុះតាមដាន។
- ជំរុញលើកទឹកចិត្តស្ត្រីមានផ្ទៃពោះ ឱ្យទៅពិនិត្យផ្ទៃពោះមុនសម្រាលនៅមណ្ឌលសុខភាព យ៉ាងហោចណាស់ ២ដង ក្នុងអំឡុងពេលមានផ្ទៃពោះ។
- មេភូមិត្រូវកត់ត្រាចំនួនស្ត្រីដែលមានអាយុពី១៥ ទៅ៤៩ឆ្នាំ នៅក្នុងភូមិរបស់ខ្លួន ហើយជូនដំណឹងទៅមណ្ឌលសុខភាពតាមរយៈក្រុមប្រឹក្សាឃុំ សង្កាត់ សម្រាប់កម្មវិធីចាក់ថ្នាំបង្ការជំងឺតេតាណូស។
- សម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងឆ្មបបុរាណ និងពេទ្យឆ្មប។
- សម្រាប់តំបន់ដាច់ស្រយាល : ត្រូវប្រាកដថាសេវាពិនិត្យផ្ទៃពោះមុនពេលសម្រាល ត្រូវបានបញ្ចូលនៅក្នុងកម្មវិធីផ្តល់សេវាចុះមូលដ្ឋាន។
- ពិចារណានូវរាល់ជម្រើសទាំងអស់ ដើម្បីរៀបចំមធ្យោបាយសង្គ្រោះបន្ទាន់នៅមូលដ្ឋាន ក្នុងករណីចាំបាច់ នៅក្នុងអំឡុងពេល ឬបន្ទាប់ពីសម្រាល។ ថវិកាឃុំ សង្កាត់បន្តិចបន្តួច អាចត្រូវបានគ្រោងនៅថវិកាឃុំ សង្កាត់ត្រង់ខ្ទង់ថវិកាលេខ៦៤ "ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ច" សម្រាប់ប្រជាពលរដ្ឋក្រីក្រដែលមិនមានលទ្ធភាពបញ្ជូនជនរងគ្រោះទៅកាន់សេវាសុខភាព។

## ចម្លើយលំហាត់ ៣.១ : ការពិនិត្យផ្ទៃពោះមុនពេលសម្រាល

| ល.រ | ការបរិយាយ | ត្រូវ | ខុស |
|---|---|---|---|
| ១ | ស្ត្រីគួរបន្ថយការបរិភោគក្នុងពេលមានផ្ទៃពោះ ដូច្នេះកូនក្នុងផ្ទៃរបស់គេនឹងតូច ហើយងាយស្រួលក្នុងការសម្រាល។ | | ✓ |
| ២ | ប្រសិនបើស្ត្រីមានផ្ទៃពោះមានសុខភាពល្អ នោះកូននៅក្នុងផ្ទៃរបស់គេភាគច្រើន នៅពេលកើតមកមានសុខភាពល្អផងដែរ។ | ✓ | |
| ៣ | ស្ត្រីត្រូវទៅពិនិត្យផ្ទៃពោះតែនៅពេលមានកូនដំបូងប៉ុណ្ណោះ។ | | ✓ |
| ៤ | នៅពេលទៅពិនិត្យសុខភាពក្នុងអំឡុងពេលមានផ្ទៃពោះ ពេទ្យឆ្មបមណ្ឌលសុខភាពនឹងផ្តល់ដំបូន្មានទៅម្តាយពីវិធីថែទាំខ្លួន និងត្រៀមរៀបចំសម្រាប់ការសម្រាលកូន។ | ✓ | |
| ៥ | ស្ត្រីមានផ្ទៃពោះត្រូវតែបានចាក់ថ្នាំបង្ការជំងឺតេតាណូសដើម្បីការពារខ្លួននិងទារក ក្នុងអំឡុងពេលសម្រាល។ | ✓ | |
| ៦ | ស្ត្រីមានផ្ទៃពោះត្រូវទៅពិនិត្យផ្ទៃពោះតែមួយលើកប៉ុណ្ណោះ នៅមណ្ឌលសុខភាព។ | | ✓ |
| ៧ | ស្ត្រីមានផ្ទៃពោះត្រូវទៅពិនិត្យផ្ទៃពោះមុនពេលសម្រាលតែនៅពេលដែលគេមានជំងឺ ឬមានបញ្ហាអ្វីមួយប៉ុណ្ណោះ។ | | ✓ |
| ៨ | ស្ត្រីមានផ្ទៃពោះគួរលេបថ្នាំគ្រាប់ជាតិដែកមួយគ្រាប់ក្នុងមួយថ្ងៃ រយៈពេល៩០ថ្ងៃ។ | ✓ | |
| ៩ | សញ្ញាគ្រោះថ្នាក់២ដែលបង្ហាញពីស្ត្រីមានផ្ទៃពោះដែលត្រូវតែទៅមណ្ឌលសុខភាព ជាបន្ទាន់ ដើម្បីទទួលការព្យាបាល គឺមានហូរឈាមតាមទ្វារមាស ហើមដៃ និងជើងធ្ងន់ធ្ងរ។ | ✓ | |
| ១០ | ស្ត្រីមានផ្ទៃពោះ ត្រូវធ្វើតេស្តរកមេរោគអេដស៍ (ការធ្វើតេស្តនេះឥតបង់ថ្លៃទេ)។ | ✓ | |

# ប្លង់មេរៀនទី៤

# ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ និងការផ្តល់អាហារបន្ថែម

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង :<br>• យល់ច្បាស់ពីផលប្រយោជន៍នៃការបំបៅកូនដោយទឹកដោះម្តាយសុទ្ធតែមួយមុខគត់<br>• មានលទ្ធភាពរៀបចំសកម្មភាពដែលត្រូវអនុវត្តដោយអាជ្ញាធរមូលដ្ឋាន ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការបំបៅកូនដោយទឹកដោះម្តាយសុទ្ធតែមួយមុខគត់។ |
| រយៈពេលសរុប | ប្រហែល ២០នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត និងឯកសារលំហាត់៤.១។ |
| វិធីសាស្ត្រ | ការបំផុសគំនិត និងការបង្ហាញ។ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៣នាទី | ១. ការផ្តើមសេចក្តី<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា "ថ្ងៃនេះយើងនឹងពិភាក្សាអំពីការផ្តល់ចំណីអាហារឱ្យកូន និងផ្នែកដទៃទៀតដែលមានផលប៉ះពាល់ខ្លាំងណាស់ទៅលើការរស់នៅសុខស្រួលរបស់កុមារក្នុងភូមិរបស់យើង"។<br><br>បន្ទាប់មកអ្នកសម្របសម្រួលជម្រាបដល់សិក្ខាកាមថា "ម្តាយត្រូវចាប់ផ្តើមបំបៅកូនដោយទឹកដោះដំបូងឱ្យបានឆាប់ជាការប្រសើរបំផុត ក្នុងចន្លោះពេលតិចជាង១ម៉ោង បន្ទាប់ពីសម្រាលកូនរួច។ ការបំបៅកូនដោយទឹកដោះម្តាយ គឺជាសេចក្តីត្រូវការតែមួយគត់របស់កុមារ ក្នុងរយៈពេល៦ខែដំបូង។ ទឹកដោះម្តាយបានផ្តល់នូវការការពារដ៏ប្រសើរបំផុតដល់កុមារ ហើយជៀសផុតពីការកើតជំងឺរាករូស ដែលបណ្តាលមកពីការប្រើប្រាស់ទឹកកខ្វក់។ | |
| ៥នាទី | ២. ការបំផុសសំណួរ<br>អ្នកសម្របសម្រួលសួរទៅកាន់សិក្ខាកាមថា "តើហេតុអ្វីបានជាថា ការបំបៅកូនដោយទឹកដោះម្តាយ គឺជាសេចក្តីត្រូវការតែមួយគត់របស់កុមារក្នុងរយៈពេល៦ខែដំបូង?"។ ចម្លើយរបស់សិក្ខាកាម ត្រូវកត់ត្រានៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៧នាទី | ៣. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់មេរៀនទី៤ : អត្ថប្រយោជន៍នៃការបំបៅកូនដោយទឹកដោះម្ដាយតែមួយមុខគត់ ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អាន។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់ និងបកស្រាយចម្ងល់របស់សិក្ខាកាម។<br>អ្នកសម្របសម្រួលបញ្ចប់សកម្មភាពនេះ ដោយបញ្ជាក់បន្ថែមថា "ទឹកដោះម្ដាយរួមផ្សំដោយសារធាតុអាហារ និងទឹករហូតដល់៨០%។ ដូច្នេះទឹកដោះមួយមុខ អាចបំពេញអ្វីដែលទារកត្រូវការ ដើម្បីធំធាត់មានកំលាំងមាំមួន និងសុខភាពល្អ"។ | ខ្លឹមសារ មេរៀនទី៤ |
| ៥នាទី | ៤. ការបង្ហាញ និងធ្វើសុពលភាព<br>អ្នកសម្របសម្រួលចែកឯកសារលំហាត់ ៤.១.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្ដល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែម ទៅក្នុងឯកសារលំហាត់៤.១ នូវសកម្មភាពដែលបានបន្ថែមទាំងនោះ។ | ឯកសារ លំហាត់៤.១ |

## ឯកសារលំហាត់ ៤.១ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- ជំរុញការបំបៅកូនដោយទឹកដោះម្ដាយតាមរយៈភ្នាក់ងារសេវាសុខភាពនៅគ្រប់ភូមិទាំងអស់ នៅក្នុងឃុំសង្កាត់។
- សម្របសម្រួល និងរៀបចំឱ្យមានការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការបំបៅកូនដោយទឹកដោះម្ដាយ។

# ប្លង់មេរៀនទី៥
# ថ្នាំបង្ការជំងឺ និងអាហារូបត្ថម្ភ

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង :<br>• យល់ដឹងអំពីថ្នាំបង្ការជំងឺដែលអាចការពារកូនរបស់គាត់ពីជំងឺ៧មុខ<br>• យល់ដឹងអំពីសារៈសំខាន់នៃជីវជាតិអា និងអំបិលអ៊ីយ៉ូដនៅក្នុងចំណីអាហាររបស់កុមារ<br>• យល់ដឹងអំពីសារៈសំខាន់នៃការទម្លាក់ព្រូនតាមពេលកំណត់<br>• មានលទ្ធភាពរៀបចំផែនការសកម្មភាព ដើម្បីបង្កើនការទទួលថ្នាំបង្ការជំងឺ ជីវជាតិអា និង ថ្នាំទម្លាក់ព្រូន នៅក្នុងឃុំ សង្កាត់។ |
| រយៈពេលសរុប | ប្រហែល ៩០នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កញ្ចប់អំបិលអ៊ីយ៉ូដ ជីវជាតិអា ថ្នាំទម្លាក់ព្រូន និងឯកសារលំហាត់៥.១។ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការបង្ហាញ និងការពិភាក្សាតាមក្រុម។ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១០នាទី | **<u>ផ្នែក "ក" : ថ្នាំបង្ការជំងឺ</u>**<br>១. ការបំផុសសំណួរ<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយបំផុសសំណួរថា "តើការចាក់ថ្នាំបង្ការជំងឺ៧មុខ មានអ្វីខ្លះ?"។ ចម្លើយរបស់សិក្ខាកាមត្រូវកត់ត្រានៅក្តារខៀន ឬក្រដាសផ្ទាំងធំ។<br>ចម្លើយអាចមាន :<br>• ថ្នាំបង្ការជំងឺរបេង<br>• ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទបេ<br>• ថ្នាំបង្ការជំងឺគ្រុនស្វិតដៃជើង<br>• ថ្នាំបង្ការជំងឺក្អកមាន់<br>• ថ្នាំបង្ការជំងឺខាន់ស្លាក់<br>• ថ្នាំបង្ការជំងឺតេតាណូស<br>• ថ្នាំបង្ការជំងឺកញ្ជ្រឹល | |
| ១០នាទី | ២. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលបញ្ជាក់បន្ថែមដល់សិក្ខាកាមថា "យើងបានដឹងហើយថាជំងឺទាំងអស់នេះ អាចការពារបាន និងត្រូវអនុវត្តគ្រប់សកម្មភាព ដើម្បីធានាថា កុមារទាំងអស់នៅក្នុងសហគមន៍របស់យើង ទទួលបានថ្នាំបង្ការជំងឺគ្រប់ចំនួន។ អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៥.១.ការផ្តល់ថ្នាំបង្ការជំងឺដល់កុមារ ហើយអញ្ជើញសិក្ខាកាមអានម្តងមួយចំណុចៗ។ បន្ទាប់មកអ្នកសម្រប | ខ្លឹមសារ មេរៀន៥.១ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | សម្រួលពន្យល់បកស្រាយ ព្រមទាំងលើកឧទាហរណ៍។ | |
| ១០នាទី | **<u>ផ្នែក "ខ" : ជីវជាតិអា</u>**<br>៣. ការបង្ហាញខ្លឹមសារមេរៀន<br>អ្នកសម្រួលសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៥.២.ជីវជាតិអា ហើយជម្រាបសិក្ខាកាមថា "ជីវជាតិអា គឺជាជីវជាតិដ៏សំខាន់មួយ សម្រាប់ការធំលូតលាស់ អភិវឌ្ឍន៍រូបរាងកាយ និងសុខភាពរបស់កុមារ និងដើម្បីការពារជំងឺខ្វាក់មាន់។ ការផ្តល់ជីវជាតិអា គឺជាផ្នែកមួយនៃសកម្មភាពផ្តល់សេវាចុះមូលដ្ឋានរបស់បុគ្គលិកមណ្ឌលសុខភាព និងត្រូវបានផ្តល់២ដងក្នុងមួយឆ្នាំ នៅខែមីនា និងខែវិច្ឆិកា សម្រាប់កុមារអាយុ៦ខែ ដល់៥៩ខែ។ ចំពោះម្តាយបន្ទាប់ពីសម្រាលកូន សេវានេះត្រូវបានផ្តល់ជាប្រចាំខែ"។ | -ជីវជាតិអា<br>-ខ្លឹមសារមេរៀន៥.២ |
| ១០នាទី | **<u>ផ្នែក "គ" : អំបិលអ៊ីយ៉ូដ</u>**<br>៤. ការបំផុសសំណួរ<br>អ្នកសម្របសម្រួលជម្រាបដល់សិក្ខាកាមថា "មានជីវជាតិផ្សេងទៀតដែលអាចបង្កជាបញ្ហាដល់រាងកាយរបស់យើង ប្រសិនបើយើងខ្វះវា" ហើយសួរសំណួរថា តើអ្នកស្គាល់អំបិលអ៊ីយ៉ូដដែរឬទេ? តើវាមានប្រយោជន៍អ្វីខ្លះ?។ ចម្លើយរបស់សិក្ខាកាមត្រូវកត់ត្រាលើក្តារខៀន ឬក្រដាសផ្ទាំងធំ។<br><br>បន្ទាប់មកអ្នកសម្របសម្រួលបង្ហាញកញ្ចប់អំបិលអ៊ីយ៉ូដ ហើយបញ្ជាក់ដល់សិក្ខាកាមថា "អំបិលដែលមានជាតិអ៊ីយ៉ូដ គឺ មានរូប ឬស្លាកសញ្ញាបែបនេះ"។ | -កញ្ចប់អំបិលអ៊ីយ៉ូដ |
| ១០នាទី | ៥. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលបន្តដោយបញ្ជាក់បន្ថែមដល់សិក្ខាកាមថា "វាមានផលប៉ះពាល់យ៉ាងច្រើន ប្រសិនបើក្នុងខ្លួនរបស់យើងគ្មានជាតិអ៊ីយ៉ូដគ្រប់គ្រាន់"។<br><br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៥.៣.អំបិលអ៊ីយ៉ូដ និងអញ្ជើញសិក្ខាកាមអាន។ បន្ទាប់ពីអានចប់ អ្នកសម្របសម្រួលបន្ថែមថា "យើងម្នាក់ៗត្រូវការជាតិអ៊ីយ៉ូដតិចតួចប៉ុណ្ណោះ ដើម្បីឱ្យមានប្រាជ្ញា និងសុខភាពមាំមួន។ ប្រសិនបើយើងប្រើតែអំបិលអ៊ីយ៉ូដ គឺគ្រប់គ្រាន់។ ដូចនេះ យើងត្រូវធានាថាមានតែអំបិលអ៊ីយ៉ូដមួយមុខគត់ដែលដាក់លក់នៅតាមទីផ្សារ"។ (យោងអនុក្រឹត្យ | -ខ្លឹមសារមេរៀន៥.៣ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | លេខ២៦៩ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដរបស់ក្រសួងសុខាភិបាល) ។ | |
| ១០នាទី | **ផ្នែក "ឃ" : ការទម្លាក់ព្រូន**<br>៦. ការបំផុសសំណួរ<br>អ្នកសម្របសម្រួលបន្តដោយលើកឡើងថា រហូតមកដល់ពេលនេះ យើងបានពិភាក្សាគ្នារួចហើយអំពីការផ្តល់ថ្នាំបង្ការ និងគ្រាប់ថ្នាំជីវជាតិអា។ ជូនកាលកូនៗរបស់អ្នកបានទទួលថ្នាំបង្ការជំងឺគ្រប់ចំនួន និងបានទទួលថ្នាំគ្រាប់ជីវជាតិអា ប៉ុន្តែពួកគេនៅតែមានជំងឺជាញឹកញាប់។ តើអ្វីទៅអាចជាមូលហេតុនៃជំងឺទាំងនេះ?។ ជំងឺនេះបណ្តាលមកពីដង្កូវក្នុងពោះវៀន ហៅថាព្រូន។<br><br>អ្នកសម្របសម្រួលជម្រាបដល់សិក្ខាកាមថា តាមរយៈសកម្មភាពផ្តល់សេវាចុះមូលដ្ឋានរបស់បុគ្គលិកមណ្ឌលសុខភាព នឹងផ្តល់ជូន២ដងក្នុងមួយឆ្នាំ "យុទ្ធនាការទម្លាក់ព្រូនក្នុងពោះវៀន"។ កម្មវិធីនេះ ក៏ត្រូវបានរៀបចំឡើង២ដងក្នុងមួយឆ្នាំផងដែរ នៅតាមសាលាបឋមសិក្សា និងនៅតាមសហគមន៍ នៅខែមីនា និងខែវិច្ឆិកា។ | ថ្នាំទម្លាក់ព្រូន |
| ១៥នាទី | ៧. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលពន្យល់បន្ថែមថា កើតព្រូនមិនមែនជាបញ្ហាសុខភាពដែលពិបាកដោះស្រាយនោះឡើយ បន្ទាប់មកស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៥.៤.ការទម្លាក់ព្រូន ហើយសុំឱ្យសិក្ខាកាមម្នាក់ ឬ២នាក់អាន។ បន្ទាប់ពីអានចប់ អ្នកសម្របសម្រួលបញ្ជាក់បន្ថែមជូនសិក្ខាកាមថា "ការទម្លាក់ព្រូន មានភាពងាយស្រួល ចំណាយលុយតិច និងពុំផ្តល់ផលរំខានទេ"។ | ខ្លឹមសារមេរៀន៥.៤ |
| ១៥នាទី | ៨. ការបង្ហាញ និងធ្វើសុពលភាព<br>អ្នកសម្របសម្រួលចែកឯកសារលំហាត់ ៥.១.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែម ទៅក្នុងឯកសារលំហាត់៥.១ នូវសកម្មភាពដែលបានបន្ថែមទាំងនោះ។ | ឯកសារលំហាត់៥.១ |






សុខភាពល្អ និង ប្រាជ្ញាឈ្លាសវៃ
សម្រាប់កុមារ គឺញ៉ាំអំបិលអ៊ីយ៉ូដ
ជាតិអ៊ីយ៉ូត គឺជាជាតិម្យ៉ាងចាំបាច់សម្រាប់ជួយឱ្យមនុស្សយើងមានសុខភាពល្អ។ កង្វះជាតិអ៊ីយ៉ូតក្នុងខ្លួនមនុស្សយើង បណ្តាលឱ្យមានបញ្ហាជាច្រើន ដូចខាងក្រោម:
១-អន់សតិបញ្ញា
២-កម្លាំងខ្សោយ
៣-ស្តាប់មិនលឺ (ថ្លង់)
៤-និយាយមិនច្បាស់
៥-កើតជម្ងឺពកក
រាងកាយលូតលាស់មាំមួន ប្រាជ្ញាឈ្លាសវៃ
អំបិលអ៊ីយ៉ូដ
ដើម្បីចៀសវាងបញ្ហាដូចបានរៀបរាប់មកនេះ គេបានលាយជាតិអ៊ីយ៉ូតជាមួយអំបិល។ ដូច្នេះបើយើងញ៉ាំអំបិលអ៊ីយ៉ូតរាល់ថ្ងៃ យើងនឹង:
១-មានប្រាជ្ញាឈ្លាសវៃ
២-មានរាងកាយលូតលាស់ធំធាត់ល្អ
៣-មានសុខភាពមាំមួន
៤-ចៀសវាងបានជម្ងឺពកក
unicef

## ឯកសារលំហាត់ ៥.១ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- រក្សា និងធ្វើបច្ចុប្បន្នភាពនូវការកត់ត្រានូវរាល់ទារកកើតថ្មី នៅគ្រប់ភូមិ ។
- ប្រើប្រាស់ភ្នាក់ងារសេវាសុខភាពសហគមន៍ ដើម្បីជូនដំណឹងដល់ឪពុកម្តាយទារកអំពីកាលបរិច្ឆេទ និងពេលវេលានៃសកម្មភាពផ្តល់សេវាចុះមូលដ្ឋាន ។
- ជំរុញ និងលើកទឹកចិត្តដល់ឪពុកម្តាយទារកឱ្យយកកូនទៅចាក់ថ្នាំបង្ការជំងឺឱ្យបានទៀតទាត់ ។
- ត្រួតពិនិត្យសកម្មភាពផ្តល់សេវាទម្លាក់ព្រូនរបស់មណ្ឌលសុខភាព តាមរយៈសកម្មភាពផ្តល់សេវាចុះមូលដ្ឋាន (នៅខែមីនា និងខែវិច្ឆិកា) និង២ដងក្នុងមួយឆ្នាំ នៅតាមសាលាបឋមសិក្សា និងសហគមន៍ ។
- ធានាដល់ការផ្សព្វផ្សាយនៃសកម្មភាពផ្តល់សេវាចុះមូលដ្ឋាន ។
- ត្រួតពិនិត្យសកម្មភាពសេវាផ្តល់ជីវជាតិអា ២ដងក្នុងមួយឆ្នាំចំពោះកុមារមានអាយុពី៦ខែ ដល់៥ឆ្នាំ និង ១ដងក្នុងមួយឆ្នាំចំពោះស្ត្រីបន្ទាប់ពីសម្រាល (អំឡុង៨សប្តាហ៍ បន្ទាប់ពីសម្រាល) ។
- ធានាថាមានតែអំបិលអ៊ីយ៉ូដមួយមុខប៉ុណ្ណោះ ត្រូវបានលក់នៅលើទីផ្សារ ។
- ផ្សព្វផ្សាយអំពីសារៈសំខាន់នៃការប្រើប្រាស់អំបិលអ៊ីយ៉ូដ តាមរយៈភ្នាក់ងារសេវាសុខភាពសហគមន៍ ។
- រាយការណ៍អំពីសកម្មភាពផ្តល់សេវាចុះមូលដ្ឋានទៅមណ្ឌលសុខភាព ។

# ប្លង់មេរៀនទី៦ : ជំងឺរាក

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង :<br>• យល់ដឹងអំពីសារៈសំខាន់នៃអនាម័យល្អ ចំពោះសុខភាព និងការអភិវឌ្ឍសហគមន៍<br>• យល់ដឹងអំពីទំនាក់ទំនងរវាងជំងឺរាក និងការខ្វះអនាម័យ ឬការខ្វះទឹកស្អាត<br>• មានលទ្ធភាពរៀបចំ និងអនុវត្តផែនការសកម្មភាពដើម្បីលើកកម្ពស់អនាម័យនៅក្នុងឃុំ សង្កាត់របស់ខ្លួន។ |
| រយៈពេលសរុប | ប្រហែល ៤៥នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ក្រដាសទំហំអា៤ និងឯកសារលំហាត់៦.១. ៦.២។ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការបង្ហាញ និងការពិភាក្សាតាមក្រុម។ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ២៥នាទី | ១. លំហាត់ ៦.១. ជំងឺរាក<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា "យើងនឹងពិភាក្សាអំពីជំងឺរាកដែលបានសម្លាប់មនុស្សអស់ជាច្រើន ប៉ុន្តែវាជាជំងឺមួយងាយស្រួលក្នុងការការពារ"។<br>អ្នកសម្របសម្រួលចែកសិក្ខាកាមជាក្រុមដែលមានសមាជិក៥-៦នាក់ ចែកឯកសារលំហាត់ ៦.១.ជំងឺរាក និងក្រដាសទំហំអា៤។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់ក្រុមនីមួយៗអំពីរបៀបធ្វើលំហាត់នេះថា : ក្រុមនីមួយៗត្រូវគិតពិចារណាឃ្លានីមួយៗ ហើយផ្តល់ចម្លើយ "ខុស" ឬ "ត្រូវ"។ បើអ្នកយល់ថាឃ្លានោះខុស អ្នកត្រូវសរសេរ "ខុស" ផ្ទុយមកវិញបើអ្នកយល់ថាឃ្លានោះត្រូវ អ្នកត្រូវសរសេរ "ត្រូវ" ហើយបិទឱ្យជិតកុំឱ្យក្រុមដទៃមើលឃើញ។<br>បន្ទាប់មកអ្នកសម្របសម្រួល យកតារាងបូកសរុបពិន្ទុដែលបានរៀបចំរួចជាស្រេចនៅលើក្រដាសផ្ទាំងធំ បិទលើក្តារខៀន ហើយចាប់ផ្តើមធ្វើលំហាត់នេះម្តងមួយៗ។ | -ក្រដាសទំហំអា៤<br>-ឯកសារលំហាត់៦.១ |
| ១០នាទី | ២. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់មេរៀនទី ៦.ជំងឺរាក ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អាន។<br>អ្នកសម្របសម្រួលជម្រាបដល់សិក្ខាកាមថា "ប្រសិនបើយើងអនុវត្តអនាម័យបានល្អត្រឹមត្រូវ យើងអាចកាត់បន្ថយ និងជៀសវាងជំងឺរាកបានយ៉ាងច្រើន នៅក្នុង | ខ្លឹមសារមេរៀនទី៦ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | គ្រួសាររបស់យើង។ ដូច្នេះយើងអាចសន្សំលុយ ចំណេញពេលវេលា និងគ្រួសារមានសុខភាពល្អ"។ | |
| ១០នាទី | ៣. ការបង្ហាញ និងធ្វើសុពលភាព<br>អ្នកសម្របសម្រួលចែកឯកសារលំហាត់ ៦.២.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមទៅក្នុងឯកសារលំហាត់៦.២ នូវសកម្មភាពដែលបានបន្ថែមទាំងនោះ។ | ឯកសារលំហាត់៦.២ |

## ឯកសារលំហាត់ ៦.១ : ជំងឺរាក

| លរ | ការបរិយាយ | ត្រូវ | ខុស |
|---|---|---|---|
| ១ | ជំងឺរាករូសបណ្តាលមកពីការហូបចំណី និងផឹកទឹកមិនស្អាត។ | | |
| ២ | ការលាងដៃបន្ទាប់ពីការបន្ទោបង់ជាទង្វើដ៏ល្អមួយ។ | | |
| ៣ | បន្ទាប់ពីលាងលាមកទារក មិនចាំបាច់លាងដៃទេ។ | | |
| ៤ | សាប៊ូ និងផេះល្អសម្រាប់ការលាងសម្អាតដៃ។ | | |
| ៥ | លាមកទារកមិនបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្សដូចលាមកមនុស្សពេញវ័យទេ។ | | |
| ៦ | អាហារគួរការពារកុំឱ្យរុយរោម ពីព្រោះរុយជាសត្វកខ្វក់ ហើយអាចបណ្តាលឱ្យមនុស្សកើតជំងឺរាករូស។ | | |
| ៧ | ប្រសិនបើអ្នកមិនមានបង្គន់ប្រើប្រាស់ ការជីករណ្តៅកប់លាមករបស់អ្នកអាចជួយកាត់បន្ថយឱកាសមានជំងឺរាកបាន។ | | |
| ៨ | ជំងឺរាករូស អាចបណ្តាលឱ្យស្លាប់។ | | |
| ៩ | កុមារដែលលាមកមានលាយឈាម ត្រូវសម្រាកឱ្យបានល្អនៅផ្ទះ។ | | |
| ១០ | ទឹកឆ្អិន (ទឹកដាំពុះ) និងទឹកចម្រោះ គឺទឹកស្អាត (មានសុវត្ថិភាព) ក្នុងការផឹក។ | | |

## តារាងបូកសរុបពិន្ទុ

| លេខរៀងឃ្លា | ចម្លើយ | | | | |
|---|---|---|---|---|---|
| | ក្រុមទី១ | ក្រុមទី២ | ក្រុមទី៣ | ក្រុមទី៤ | ក្រុមទី៥ |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |
| ១០ | | | | | |
| សរុបពិន្ទុ | | | | | |

## ឯកសារលំហាត់ ៦.២ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- បញ្ឈប់ការបន្ទោបង់លាមកនៅតាមទីវាល នៅគ្រប់ភូមិ ក្នុងឃុំ សង្កាត់ តាមរយៈការជំរុញការប្រើប្រាស់ និងសាងសង់បង្គន់អនាម័យ ។
- ជំរុញយុទ្ធនាការអនាម័យ ក្នុងការទុកដាក់ឱ្យបានត្រឹមត្រូវល្អនូវកាកសំណល់របស់សត្វ និងមនុស្ស ។
- វិនិយោគទៅលើទឹកស្អាត និងអនាម័យសាធារណៈ ។
- ជំរុញការលាងសម្អាតដៃរបស់កុមារ នៅតាមសាលារៀន ។
- សហការជាមួយមណ្ឌលសុខភាព និងភ្នាក់ងារសេវាសុខភាពមូលដ្ឋាន អំពីការលើកកម្ពស់អនាម័យ ។
- ធានាដល់ការការពារប្រភពទឹករបស់សហគមន៍ ។

## ចម្លើយលំហាត់ ៦.១ : ជំងឺរាក

| លរ | ការបរិយាយ | ត្រូវ | ខុស |
|---|---|---|---|
| ១ | ជំងឺរាករូសបណ្តាលមកពីការហូបចំណី និងផឹកទឹកមិនស្អាត ។ | ✓ | |
| ២ | ការលាងដៃបន្ទាប់ពីការបន្ទោបង់ជាទម្លាប់ល្អមួយ ។ | ✓ | |
| ៣ | បន្ទាប់ពីលាងលាមកទារក មិនចាំបាច់លាងដៃទេ ។ | | ✓ |
| ៤ | សាប៊ូ និងផេះល្អសម្រាប់ការលាងសម្អាតដៃ ។ | ✓ | |
| ៥ | លាមកទារកមិនបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្សដូចលាមកមនុស្សពេញវ័យទេ ។ | | ✓ |
| ៦ | អាហារគួរការពារកុំឱ្យរុយរោម ពីព្រោះរុយជាសត្វកខ្វក់ ហើយអាចបណ្តាលឱ្យមនុស្សកើតជំងឺរាករូស ។ | ✓ | |
| ៧ | ប្រសិនបើអ្នកមិនមានបង្គន់ប្រើប្រាស់ ការជីករណ្តៅកប់លាមករបស់អ្នកអាចជួយកាត់បន្ថយឱកាសមានជំងឺរាកបាន ។ | ✓ | |
| ៨ | ជំងឺរាករូស អាចបណ្តាលឱ្យស្លាប់ ។ | ✓ | |
| ៩ | កុមារដែលលាមកមានលាយឈាម ត្រូវសម្រាកឱ្យបានល្អនៅផ្ទះ ។ | | ✓ |
| ១០ | ទឹកឆ្អិន (ទឹកដាំពុះ) និងទឹកចម្រោះ គឺទឹកស្អាត (មានសុវត្ថិភាព) ក្នុងការផឹក ។ | ✓ | |

# ប្លង់មេរៀនទី៧
# ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង :<br>• យល់ដឹងអំពីមូលហេតុនៃជំងឺគ្រុនចាញ់ និងវិធីការពារ<br>• យល់ដឹងអំពីមូលហេតុនៃជំងឺគ្រុនឈាម និងវិធីការពារ<br>• មានលទ្ធភាពបង្កើតផែនការសកម្មភាពដើម្បីលើកកម្ពស់ការប្រើប្រាស់មុង ក្នុងការការពារជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម ។ |
| រយៈពេលសរុប | ប្រហែល ៥៥នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ក្រដាសទំហំអា៤ និងឯកសារលំហាត់ ៧.១. ៧.២។ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការធ្វើបង្ហាញ និងការពិភាក្សាតាមក្រុម ។ |

សកម្មភាពសម្របសម្រួលមេរៀន :

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៣នាទី | ១. ការផ្តើមសេចក្តី<br>អ្នកសម្របសម្រួលជម្រាបដល់សិក្ខាកាមថា "ដូចបញ្ហាសុខភាពផ្សេងៗទៀតដែលយើងបានពិភាក្សាគ្នារួចមកហើយ ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម គឺជាជំងឺដែលអាចការពារបាន បើអ្នកទាំងអស់គ្នានៅក្នុងសហគមន៍ បានអនុវត្តតាមការណែនាំត្រឹមត្រូវ ឬបើកើតជំងឺនេះហើយ ត្រូវសង្គ្រោះជីវិតដោយធ្វើការព្យាបាលពីដំបូង"។ | |
| ១៥នាទី | ២. លំហាត់ ៧.១.ជំងឺគ្រុនចាញ់ និងគ្រុនឈាម<br>អ្នកសម្របសម្រួលចែកសិក្ខាកាមជាក្រុមដែលមានសមាជិក៥-៦នាក់ ចែកឯកសារលំហាត់ ៧.១.ជំងឺគ្រុនចាញ់ និងគ្រុនឈាម និងក្រដាសទំហំអា៤។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់ក្រុមនីមួយៗអំពីរបៀបធ្វើលំហាត់នេះថា : ក្រុមនីមួយៗត្រូវគិតពិចារណាឃ្លានីមួយៗ ហើយផ្តល់ចម្លើយ "ខុស" ឬ "ត្រូវ"។ បើអ្នកយល់ថាឃ្លានោះខុស អ្នកត្រូវសរសេរ "ខុស" ផ្ទុយមកវិញបើអ្នកយល់ថាឃ្លានោះត្រូវ អ្នកត្រូវសរសេរ "ត្រូវ" ហើយបិទឱ្យជិតកុំឱ្យក្រុមដទៃមើលឃើញ។<br>បន្ទាប់មកអ្នកសម្របសម្រួល យកតារាងបូកសរុបពិន្ទុដែលបានរៀបចំរួចជាស្រេចនៅលើក្រដាសផ្ទាំងធំ បិទលើក្តារខៀន ហើយចាប់ផ្តើមធ្វើលំហាត់នេះម្តង១មួយ ។ | -ក្រដាសទំហំអា៤<br>-ឯកសារលំហាត់៧.១ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១០នាទី | ៣. ការបំផុសសំណួរ<br>អ្នកសម្របសម្រួលបញ្ជាក់ដល់សិក្ខាកាមថា "ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម គឺជាជំងឺដ៏គ្រោះថ្នាក់ធ្ងន់ធ្ងរ ដែលឆ្លងតាមរយៈមូសខាំ ប៉ុន្តែជំងឺទាំងពីរនេះមានចំណុចខុសគ្នាខ្លះ តើខុសគ្នាយ៉ាងដូចម្តេច?"។ ចម្លើយរបស់សិក្ខាកាមត្រូវកត់ត្រានៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ ។<br>ចម្លើយអាចមាន :<br>• បណ្តាលមកពីមូសប្រភេទខុសគ្នា ( មូសដែកគោលញីចម្លងជំងឺគ្រុនចាញ់ មូសខ្លាចម្លងជំងឺគ្រុនឈាម)<br>• មានរោគសញ្ញាខុសគ្នា<br>រោគសញ្ញាជំងឺគ្រុនចាញ់ :<br>- ក្តៅខ្លាំង<br>- ញាក់<br>- ឈឺក្បាលខ្លាំង<br>- បែកញើស<br>រោគសញ្ញាជំងឺគ្រុនឈាម :<br>- ក្តៅខ្លួនខ្លាំងភ្លាមៗលើសពី២ថ្ងៃ<br>- មានកន្ទួលក្រហមលើស្បែក<br>- ឈឺក្បាល និងឈឺខ្លួនប្រាណ | |
| ៥នាទី | ៤. ការបំផុសសំណួរ<br>អ្នកសម្របសម្រួលបន្តដោយលើកឡើងថា "ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាមមានគ្រោះថ្នាក់ចំពោះមនុស្សទូទៅ ជាពិសេសចំពោះស្ត្រីមានផ្ទៃពោះ និងកុមារ។ តើហេតុអ្វីបានជាដូច្នេះ?"។<br>ចម្លើយអាចមាន:<br>• ស្ត្រីមានផ្ទៃពោះ : បង្កការលំបាកនានា ដូចជាកូនស្លាប់ក្នុងផ្ទៃ និងម្តាយអាចស្លាប់នៅពេលសម្រាល ។<br>• កុមារ : ពន្យារការលូតលាស់ និងការរីកចម្រើននៃខួរក្បាល ខ្សោយថាមពលពុំអាចធុននឹងជំងឺបាន ។ | |
| ៥នាទី | ៥. ការបំផុសសំណួរ<br>អ្នកសម្របសម្រួលបន្តដោយសួរសំណួរថា "តើឪពុកម្តាយត្រូវធ្វើដូចម្តេច នៅពេលសង្ស័យថា កូនកើតជំងឺគ្រុនចាញ់ ឬកើតជំងឺគ្រុនឈាម?"។ ចម្លើយសិក្ខាកាមត្រូវកត់ត្រានៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ ។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ចម្លើយអាចមាន :<br>• បញ្ជូនកុមារទៅមណ្ឌលសុខភាព<br>• បញ្ជូនកុមារទៅមន្ទីរពេទ្យបង្អែក<br>• បញ្ជូនកុមារទៅពេទ្យឯកជន<br>អ្នកសម្របសម្រួលបញ្ចប់សកម្មភាពនេះដោយបញ្ជាក់ដល់សិក្ខាកាមថា "ឪពុកម្តាយត្រូវប្រុងប្រយ័ត្នខ្ពស់ នៅពេលអ្នកជំងឺមានអាការគ្រុនក្តៅខ្លាំង ហើយមានការសង្ស័យថាកើតជំងឺគ្រុនចាញ់ ឬគ្រុនឈាម ត្រូវប្រញាប់យកអ្នកជំងឺទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យជាបន្ទាន់"។ | |
| ១៥នាទី | ៦. ការពិភាក្សាក្រុមតូច<br>អ្នកសម្របសម្រួលបន្តដោយលើកឡើងថា "ថ្វីត្បិតតែជំងឺគ្រុនចាញ់ និងគ្រុនឈាមជាជំងឺដ៏គ្រោះថ្នាក់ក៏ដោយ ក៏ប៉ុន្តែជំងឺទាំង២នេះអាចការពារបាន បើយើងអនុវត្តតាមការណែនាំឱ្យបានត្រឹមត្រូវ"។<br><br>បន្ទាប់មកអ្នកសម្របសម្រួលចែកសិក្ខាកាមជា៤ក្រុម។ សិក្ខាកាម២ក្រុមពិភាក្សាអំពី "វិធីការពារជំងឺគ្រុនឈាម" និង ២ក្រុមទៀតពិភាក្សាអំពី "វិធីការពារជំងឺគ្រុនចាញ់"។ ក្រុមនីមួយៗមានរយៈពេល១០នាទី ដើម្បីពិភាក្សា។ តំណាងក្រុមនីមួយៗ ឡើងបង្ហាញលទ្ធផលរបស់ក្រុមខ្លួន។<br><br>ចម្លើយអាចមានសម្រាប់ជំងឺគ្រុនចាញ់ :<br>• ទោះថ្ងៃ ឬយប់ត្រូវសម្រាន្តក្នុងមុងឱ្យបានត្រឹមត្រូវ (ត្រង់ចំណុចនេះអ្នកអាចសួរសិក្ខាកាមថា តើអ្នកណាខ្លះសម្រាន្តក្នុងមុង?)<br>• មុងត្រូវជ្រលក់ថ្នាំ ដើម្បីកុំឱ្យមូសទុំបាន<br><br>ចម្លើយអាចមានសម្រាប់ជំងឺគ្រុនឈាម :<br>• គ្របសម្ភារផ្ទុកទឹកឱ្យបានជិតល្អរៀងរាល់ពេល<br>• លុប ឬបង្ហូរទឹកចេញពីកន្លែងដែលមានដក់ទឹក<br>• ធ្វើអនាម័យសម្អាតជុំវិញផ្ទះ (កាប់ឆ្ការព្រៃជុំវិញផ្ទះ ប្រមូលវត្ថុដែលអាចដក់ទឹកបានយកទៅដុត ឬកប់ចោល ឬផ្កាប់វាឱ្យបានស្ងួតល្អ) | ក្រដាសផ្ទាំងធំ ហ្វឺត និងស្កុត |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | អ្នកសម្របសម្រួលបូកសរុបលទ្ធផលក្រុមពិភាក្សា ហើយបញ្ជាក់ដល់សិក្ខាកាមថា "បើយើងអាចការពារខ្លួន មិនឱ្យមូសខាំបាន នោះយើងអាចការពារការកើតជំងឺគ្រុនចាញ់ និងគ្រុនឈាមបានហើយ"។ | |
| ៦នាទី | ៧. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន<br>បន្ទាប់មកអ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់មេរៀនទី ៧.ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អាន។ | ខ្លឹមសារមេរៀនទី៧ |
| ៦នាទី | ៨. ការបង្ហាញ និងធ្វើសុពលភាព<br>អ្នកសម្របសម្រួលចែកឯកសារលំហាត់ ៧.២.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្ដល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមទៅក្នុងឯកសារលំហាត់ ៧.២ នូវសកម្មភាពដែលបានបន្ថែមទាំងនោះ។ | ឯកសារលំហាត់៧.២ |

## ឯកសារលំហាត់ ៧.១ : ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម

| លរ | ការបរិយាយ | ត្រូវ | ខុស |
|---|---|---|---|
| ១ | ជំងឺគ្រុនចាញ់មាននៅគ្រប់ទីកន្លែងទាំងអស់ នៅក្នុងប្រទេសកម្ពុជា។ | | |
| ២ | ជំងឺគ្រុនចាញ់អាចឆ្លងតាមរយៈទឹកទន្លេដែលកខ្វក់។ | | |
| ៣ | ជំងឺគ្រុនចាញ់បណ្ដាលឱ្យគ្រុនក្ដៅយ៉ាងខ្លាំង និងត្រូវតែធ្វើការព្យាបាល។ | | |
| ៤ | ជំងឺគ្រុនចាញ់អាចឆ្លងតាមធូលីដីផ្លូវពីតំបន់ដែលមានគ្រុនចាញ់។ | | |
| ៥ | អ្នកអាចកើតជំងឺគ្រុនចាញ់ នៅតែតំបន់ព្រៃប៉ុណ្ណោះ។ | | |
| ៦ | រោគសញ្ញានៃជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម គឺដូចគ្នា។ | | |
| ៧ | មានតែកុមារប៉ុណ្ណោះដែលកើតជំងឺគ្រុនឈាម មនុស្សពេញវ័យមិនកើតជំងឺគ្រុនឈាមទេ។ | | |
| ៨ | ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម បណ្ដាលមកពីមូសប្រភេទខុសគ្នា។ | | |
| ៩ | ជំងឺគ្រុនចាញ់ មានគ្រោះថ្នាក់ ជាពិសេសស្ត្រីមានផ្ទៃពោះ។ | | |
| ១០ | អ្នកអាចកើតជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម តែនៅក្នុងអំឡុងពេលរដូវភ្លៀងប៉ុណ្ណោះ។ | | |

## តារាងបូកសរុបពិន្ទុ

| លេខរៀងឃ្លា | ចម្លើយ | | | | |
|---|---|---|---|---|---|
| | ក្រុមទី១ | ក្រុមទី២ | ក្រុមទី៣ | ក្រុមទី៤ | ក្រុមទី៥ |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |
| ១០ | | | | | |
| សរុបពិន្ទុ | | | | | |

## ឯកសារលំហាត់ ៧.២ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- សហការជាមួយមណ្ឌលសុខភាព និងភ្នាក់ងារសេវាសុខភាពសហគមន៍ ដើម្បីផ្សព្វផ្សាយអំពីការការពារ និងការបង្ការជំងឺ ។
- ជំរុញឱ្យប្រជាពលរដ្ឋធ្វើការសម្អាតជុំវិញបរិវេណផ្ទះ ។
- រាយការណ៍ជូនមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក នៅក្នុងករណីជំងឺផ្ទុះឡើង ឬសង្កេតឃើញមានការផ្ទុះឡើងនូវជំងឺ ។
- សហការ និងសម្របសម្រួលក្នុងការបញ្ជូនកុមារដែលកើតជំងឺទៅកាន់មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក ។
- ជួយដល់ប្រជាពលរដ្ឋឱ្យទទួលបានមុង ។
- ជំរុញប្រជាពលរដ្ឋឱ្យប្រើប្រាស់មុង ។

## ចម្លើយលំហាត់ ៧.១ : ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម

| លរ | ការបរិយាយ | ត្រូវ | ខុស |
|---|---|---|---|
| ១ | ជំងឺគ្រុនចាញ់មាននៅគ្រប់ទីកន្លែងទាំងអស់ នៅក្នុងប្រទេសកម្ពុជា ។ | | ✓ |
| ២ | ជំងឺគ្រុនចាញ់អាចឆ្លងតាមរយៈទឹកទន្លេដែលកខ្វក់ ។ | | ✓ |
| ៣ | ជំងឺគ្រុនចាញ់បណ្តាលឱ្យគ្រុនក្តៅយ៉ាងខ្លាំង និងត្រូវតែធ្វើការព្យាបាល ។ | ✓ | |
| ៤ | ជំងឺគ្រុនចាញ់អាចឆ្លងតាមធូលីដីផ្លូវពីតំបន់ដែលមានគ្រុនចាញ់ ។ | | ✓ |
| ៥ | អ្នកអាចកើតជំងឺគ្រុនចាញ់ នៅតែតំបន់ព្រៃប៉ុណ្ណោះ ។ | | ✓ |
| ៦ | រោគសញ្ញានៃជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម គឺដូចគ្នា ។ | | ✓ |
| ៧ | មានតែកុមារប៉ុណ្ណោះដែលកើតជំងឺគ្រុនឈាម មនុស្សពេញវ័យមិនកើតជំងឺគ្រុនឈាមទេ ។ | | ✓ |
| ៨ | ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម បណ្តាលមកពីមូសប្រភេទខុសគ្នា ។ | ✓ | |
| ៩ | ជំងឺគ្រុនចាញ់ មានគ្រោះថ្នាក់ ជាពិសេសស្ត្រីមានផ្ទៃពោះ ។ | ✓ | |
| ១០ | អ្នកអាចកើតជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម តែនៅក្នុងអំឡុងពេលរដូវភ្លៀងប៉ុណ្ណោះ ។ | | ✓ |

# ប្លង់មេរៀនទី៨
# មេរោគអេដស៍ ឬជំងឺអេដស៍

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង :<br>• យល់ច្បាស់អំពីវិធីការពារខ្លួនពីការឆ្លងមេរោគអេដស៍ ឬជំងឺអេដស៍<br>• ចងចាំពីលេខទូរស័ព្ទពិសេស និងសេវាផ្តល់ប្រឹក្សាដោយស្ម័គ្រចិត្ត និងអាចទុកចិត្តបានពីការធ្វើតេស្តឈាម ដែលមាននៅតាមខេត្ត ក្រុង<br>• មានលទ្ធភាពរៀបចំផែនការសកម្មភាព ដើម្បីធានាថាប្រជាពលរដ្ឋទទួលបាននូវសេវាទាំងនេះ ។ |
| រយៈពេលសរុប | ប្រហែល ៤០នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ក្រដាសទំហំអា៤ និងឯកសារលំហាត់៨.១, ៨.២ ។ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការបង្ហាញ និងការពិភាក្សាតាមក្រុម ។ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១៥នាទី | **១. លំហាត់ ៨.១.ការឆ្លងនៃមេរោគអេដស៍ ឬជំងឺអេដស៍**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា "យើងបានពិភាក្សាជាមួយគ្នាអំពីបញ្ហាសុខភាពមួយចំនួនមកហើយ នៅពេលនេះយើងនឹងពិភាក្សាគ្នាអំពីបញ្ហាសុខភាពមួយទៀត គឺអំពីមេរោគអេដស៍ ឬជំងឺអេដស៍ ។<br>អ្នកសម្របសម្រួលចែកសិក្ខាកាមជាក្រុម ដែលមានសមាជិក៥-៦នាក់ ចែកឯកសារលំហាត់ ៨.១.ការឆ្លងនៃមេរោគអេដស៍ ឬជំងឺអេដស៍ និងក្រដាសទំហំអា៤ ។ បន្ទាប់មកទៀតអ្នកសម្របសម្រួលពន្យល់ក្រុមនីមួយៗ អំពីរបៀបធ្វើលំហាត់នេះថា : ក្រុមនីមួយៗ ត្រូវគិតពិចារណាឃ្លានីមួយៗ ហើយផ្តល់ចម្លើយ "ខុស" ឬ "ត្រូវ" ។ បើអ្នកយល់ថាឃ្លានោះខុស អ្នកត្រូវសរសេរ "ខុស" ផ្ទុយមកវិញបើអ្នកយល់ថាឃ្លានោះត្រូវ អ្នកត្រូវសរសេរ "ត្រូវ" ហើយបិទឱ្យជិតកុំឱ្យក្រុមដទៃមើលឃើញ ។ បន្ទាប់មកអ្នកសម្របសម្រួល យកតារាងបូកសរុបពិន្ទុដែលបានរៀបចំរួចជាស្រេចនៅលើក្រដាសផ្ទាំងធំ បិទលើក្តារខៀន ហើយចាប់ផ្តើមធ្វើលំហាត់នេះម្តងមួយៗ ។ | -ក្រដាសទំហំអា៤<br>-ឯកសារលំហាត់៨.១ |
| ៣នាទី | **២. ការបំផុសសំណួរ**<br>អ្នកសម្របសម្រួលបិទ "រូបអ្នកប្រដាល់" "អ្នកហែលទឹក" និង "និមិត្តសញ្ញាបូណ៌ពណ៌ក្រហម" នៅលើក្តារខៀន ហើយសួរសំណួរថា តើរូបទាំងនេះមានអត្ថន័យយ៉ាងដូចម្តេច? ។ ចម្លើយសិក្ខាកាមត្រូវកត់ត្រានៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ ។ | រូបភាព "អ្នកប្រដាល់" "អ្នកហែលទឹក" និង "និមិត្តសញ្ញា |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ចម្លើយអាចមាន :<br>• រូបភាពអ្នកប្រដាល់ មានន័យថា ឈ្លាសវៃ គឺទៅពិនិត្យឈាមដែលផ្ដល់ការប្រឹក្សាអំពីអេដស៍<br>• រូបភាពអ្នកហែលទឹក មានន័យថា អ្នកមានអេដស៍ក៏អាចហែលទឹកជាមួយខ្ញុំបានដែរ<br>• និមិត្តសញ្ញាបូណិពណិក្រហម មានន័យថា ការប្រយុទ្ធប្រឆាំងទប់ស្កាត់ការរីករាលដាលជំងឺអេដស៍ ការលើកស្ទួយ និងគាំទ្រលើកទឹកចិត្តអ្នកជំងឺអេដស៍។ | បូណិពណិក្រហម" |
| ៣នាទី | ៣. ការបំផុសសំណួរ<br>អ្នកសម្របសម្រួលបន្តដោយលើកឡើងថា "បើអ្នកចង់ដឹងព័ត៌មានអំពីមេរោគអេដស៍ ឬជំងឺអេដស៍ អ្នកអាចទូរស័ព្ទទៅកាន់លេខពិសេស "ឥន្ទធនូ"។ តាមរយៈលេខពិសេសនេះ អ្នកអាចទទួលបាននូវគ្រប់ព័ត៌មានអំពីមេរោគដេស៍ ឬជំងឺអេដស៍ដែលអ្នកចង់ដឹង" ហើយសួរសំណួរថា "តើអ្នកណាខ្លះស្គាល់ ឬចងចាំលេខទូរស័ព្ទពិសេសដែលមិនគិតថ្លៃទាំងនេះ?។<br>ចម្លើយ : លេខទូរស័ព្ទពិសេសដែលឥតគិតថ្លៃ ក្នុងការប្រឹក្សាអំពីបញ្ហាមេរោគអេដស៍ ឬជំងឺអេដស៍ :<br>• ០១២ ៩៩៩ ០០៨<br>• ០១២ ៩៩៩ ០០៩<br>• ០៩២ ៩១៤ ១១១ | |
| ២នាទី | ៤. ការបំផុសសំណួរ<br>អ្នកសម្របសម្រួលបន្តដោយសួរសំណួរថា "ប្រសិនបើអ្នកចង់ដឹងថាខ្លួនមានផ្ទុកមេរោគអេដស៍ ឬអត់ តើត្រូវធ្វើយ៉ាងដូចម្ដេច?" បន្ទាប់ពីការផ្ដល់ចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលបន្តសំណួរ តើទីកន្លែងណាខ្លះដែលផ្ដល់សេវាធ្វើតេស្តឈាមរកមេរោគអេដស៍ដែលអាចទុកចិត្តបាន?"។ ចម្លើយសិក្ខាកាមត្រូវកត់ត្រានៅលើក្ដារខៀន ឬក្រដាសផ្ទាំងធំ។<br>ចម្លើយអាចមាន :<br>• ដើម្បីឱ្យដឹងថា រូបអ្នកមានផ្ទុកមេរោគអេដស៍ ឬអត់ គឺត្រូវធ្វើការពិនិត្យឈាម<br>• ទីកន្លែងផ្ដល់សេវាធ្វើតេស្តឈាមរកមេរោគអេដស៍ដែលអាចទុកចិត្តបាន គឺទីកន្លែងដែលមានរូបសញ្ញាបូណិពណិក្រហម។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១០នាទី | ៥. ការបំផុសសំណួរ និងបង្ហាញខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលបន្តដោយសួរសំណួរថា "តើមានអ្នកផ្ទុកមេរោគអេដស៍ ឬជំងឺអេដស៍ប៉ុន្មាននាក់ នៅក្នុងសហគមន៍របស់អ្នក? បន្ទាប់មកបញ្ជាក់ដល់សិក្ខាកាមថា "នៅដំណាច់ឆ្នាំ២០០៣ សរុបអ្នកមានផ្ទុកមេរោគអេដស៍ ឬជំងឺអេដស៍ចំនួន ១២៣.១០០នាក់ ដែលក្នុងនោះមានចំនួន៥៧.៥០០នាក់ជាស្ត្រី និង ៦៥.៦០០នាក់ជាបុរស (កុមារមានចំនួនរវាងពី៧.៣០០នាក់ទៅ១២.០០០នាក់ជាកុមារ)"។ អ្នកសម្របសម្រួល ស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់មេរៀនទី៨.មេរោគអេដស៍ ឬជំងឺអេដស៍ ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អាន។<br><br>អ្នកសម្របសម្រួលបញ្ចប់សកម្មភាពនេះដោយបញ្ជាក់ដល់សិក្ខាកាម "នៅពេលដែលអ្នកដឹកនាំទាំងឡាយ បង្ហាញពីឆន្ទៈនយោបាយ និងប្ដេជ្ញាអនុវត្តសកម្មភាព នោះពួកគេនឹងទទួលជោគជ័យ ក្នុងការកាត់បន្ថយការរាលដាលនៃជំងឺអេដស៍ និងបញ្ឈប់មហន្តរាយរបស់វា។ នេះគឺជាការពិត ទាំងនៅថ្នាក់មូលដ្ឋាន ក៏ដូចជាថ្នាក់ជាតិដែរ ទាំងប្រទេសក្រីក្រក៏ដូចជាប្រទេសអ្នកមានដែរ"។ | ខ្លឹមសារមេរៀនទី៨ |
| ៧នាទី | ៦. ការបង្ហាញ និងធ្វើសុពលភាព<br>អ្នកសម្របសម្រួលចែកឯកសារលំហាត់ ៨.២.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្ដល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែម ទៅក្នុងឯកសារលំហាត់៨.២ នូវសកម្មភាពដែលបានបន្ថែមទាំងនោះ។ | ឯកសារលំហាត់៨.២ |

## ឯកសារលំហាត់ ៨.១ : ការឆ្លងមេរោគអេដស៍ ឬជំងឺអេដស៍

| លរ | មេរោគអេដស៍ ឬជំងឺអេដស៍អាចឆ្លងតាមរយៈ | ត្រូវ | ខុស |
|---|---|---|---|
| ១ | ការប៉ះពាល់ ការអោប ឬការថើបអ្នកផ្ទុកមេរោគអេដស៍ ។ | | |
| ២ | ពីម្តាយផ្ទុកមេរោគអេដស៍ទៅទារកនៅក្នុងផ្ទៃ នៅពេលសម្រាល និងនៅពេលបំបៅដោះ ។ | | |
| ៣ | មិនមែនគ្រប់កូនដែលកើតពីម្តាយផ្ទុកមេរោគអេដស៍ សុទ្ធតែឆ្លងមេរោគអេដស៍ទាំងអស់ទេ ។ | | |
| ៤ | ការញ៉ាំអាហាររួមជាមួយអ្នកផ្ទុកមេរោគអេដស៍ ។ | | |
| ៥ | ឈាមរបស់អ្នកផ្ទុកមេរោគអេដស៍ចូលក្នុងរាងកាយតាមរយៈការប្រើប្រាស់ម្ជុល ឬសឺរ៉ាំងរួមគ្នា ឬមុខរបូសស្បែកមុតថ្មី ។ | | |
| ៦ | ការថែទាំអ្នកជំងឺអេដស៍ ។ | | |
| ៧ | ការរស់នៅជាមួយគ្នា ។ | | |
| ៨ | ការរួមភេទជាមួយដៃគូដែលមានផ្ទុកមេរោគអេដស៍ ដោយមិនបានប្រើប្រាស់ស្រោមអនាម័យត្រឹមត្រូវ ។ | | |
| ៩ | ការញ៉ាំចំណីអាហារដែលអ្នកផ្ទុកមេរោគអេដស៍ចំអិន ។ | | |
| ១០ | ការរៀនសូត្រនៅក្នុងថ្នាក់ជាមួយអ្នកផ្ទុកមេរោគអេដស៍ ។ | | |

## តារាងបូកសរុបពិន្ទុ

| លេខរៀងឃ្លា | ចម្លើយ | | | | |
|---|---|---|---|---|---|
| | ក្រុមទី១ | ក្រុមទី២ | ក្រុមទី៣ | ក្រុមទី៤ | ក្រុមទី៥ |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |
| ១០ | | | | | |
| សរុបពិន្ទុ | | | | | |

## ចម្លើយលំហាត់ ៨.១ : ការឆ្លងនៃមេរោគអេដស៍ ឬជំងឺអេដស៍

| លរ | មេរោគអេដស៍ ឬជំងឺអេដស៍អាចឆ្លងតាមរយៈ | ត្រូវ | ខុស |
|---|---|---|---|
| ១ | ការប៉ះពាល់ ការអោប ឬការថើបអ្នកផ្ទុកមេរោគអេដស៍ ។ | | ✓ |
| ២ | ពីម្តាយផ្ទុកមេរោគអេដស៍ទៅទារកនៅក្នុងផ្ទៃ នៅពេលសម្រាល និងនៅពេលបំបៅដោះ ។ | ✓ | |
| ៣ | មិនមែនគ្រប់កូនដែលកើតពីម្តាយផ្ទុកមេរោគអេដស៍ សុទ្ធតែឆ្លងមេរោគអេដស៍ទាំងអស់ទេ ។ | ✓ | |
| ៤ | ការញ៉ាំអាហាររួមជាមួយអ្នកផ្ទុកមេរោគអេដស៍ ។ | | ✓ |
| ៥ | ឈាមរបស់អ្នកផ្ទុកមេរោគអេដស៍ចូលក្នុងរាងកាយតាមរយៈការប្រើប្រាស់ម្ជុល ឬសេរ៉ាំងរួមគ្នា ឬមុខរបួសស្បែកមុតថ្មី ។ | ✓ | |
| ៦ | ការថែទាំអ្នកជំងឺអេដស៍ ។ | | ✓ |
| ៧ | ការរស់នៅជាមួយគ្នា ។ | | ✓ |
| ៨ | ការរួមភេទជាមួយដៃគូដែលមានផ្ទុកមេរោគអេដស៍ ដោយមិនបានប្រើប្រាស់ស្រោមអនាម័យត្រឹមត្រូវ ។ | ✓ | |
| ៩ | ការញ៉ាំចំណីអាហារដែលអ្នកផ្ទុកមេរោគអេដស៍ចំអិន ។ | | ✓ |
| ១០ | ការរៀនសូត្រនៅក្នុងថ្នាក់ជាមួយអ្នកផ្ទុកមេរោគអេដស៍ ។ | | ✓ |




រូបអ្នកប្រដាល់



និមិត្តសញ្ញាបូណឺពណ៌ក្រហម




រូបអ្នកហែលទឹក

## ឯកសារលំហាត់ ៨.២ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- ជំរុញលើកទឹកចិត្តប្រជាពលរដ្ឋដែលមានផ្ទុកមេរោគអេដស៍ឱ្យទទួលបានថ្នាំព្យាបាល និងពន្យារជីវិត
- សហការជាមួយមណ្ឌលសុខភាព និងវត្តអារាម ក្នុងការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋកុំឱ្យរើសអើងចំពោះអ្នកផ្ទុកមេរោគអេដស៍ និងអ្នកកើតជំងឺអេដស៍
- សហការជាមួយវត្តអារាម សហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីគាំទ្រដល់អ្នក (ជាពិសេសកុមារ) ដែលផ្ទុកមេរោគអេដស៍ ឬអ្នកកើតជំងឺអេដស៍
- សហការជាមួយកម្មវិធីបង្ការការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍
- ជំរុញគូដណ្តឹង និងអ្នករៀបអាពាហ៍ពិពាហ៍ថ្មីថ្មោង ឱ្យទៅធ្វើតេស្តឈាម (២ដងក្នុងចន្លោះពេល៣ខែ)
- ជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យធ្វើតេស្តឈាមដើម្បីរកមេរោគអេដស៍

# ប្លង់មេរៀនទី៩
# ជំងឺផ្តាសាយបក្សី

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង :<br>• យល់ដឹងអំពីសញ្ញាណ របៀបឆ្លងរាលដាល និងវិធានការការពារនៃជំងឺផ្តាសាយបក្សី<br>• មានលទ្ធភាពរៀបចំផែនការសកម្មភាព ដើម្បីជួយប្រជាពលរដ្ឋ ក្នុងករណីជំងឺផ្តាសាយបក្សីផ្ទុះឡើង |
| រយៈពេលសរុប | ប្រហែល ៣៥នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត និងឯកសារលំហាត់៩.១។ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការបង្ហាញ និងការពិភាក្សាតាមក្រុម។ |

សកម្មភាពសម្របសម្រួលមេរៀន :

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | **១. ការបំផុសសំណួរ**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា "យើងបានពិភាក្សាជាមួយគ្នាអំពីបញ្ហាសុខភាពមួយចំនួនរួចហើយ នៅពេលនេះយើងនឹងពិភាក្សាគ្នាអំពីបញ្ហាសុខភាពមួយទៀត គឺអំពីជំងឺផ្តាសាយបក្សី។<br><br>បន្ទាប់មកអ្នកសម្របសម្រួលបំផុសសំណួរថា តើអ្នកធ្លាប់ឮ ឬដឹងអំពីជំងឺផ្តាសាយបក្សីដែរឬទេ? តើជំងឺនេះឆ្លងរាលដាលយ៉ាងដូចម្តេច? តើការការពារកុំឱ្យឆ្លងជំងឺនេះដោយរបៀបណា?។<br>ចម្លើយរបស់សិក្ខាកាមត្រូវកត់ត្រានៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ | |
| ២០នាទី | **២. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន**<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់មេរៀនទី ៩.ជំងឺផ្តាសាយបក្សី ហើយអញ្ជើញសិក្ខាកាមអានម្តងមួយចំណុច១។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ ព្រមទាំងលើកឧទាហរណ៍។ | ខ្លឹមសារមេរៀនទី៩ |
| ៣នាទី | **៣. ការបញ្ជាក់**<br>អ្នកសម្របសម្រួលបន្តដោយបញ្ជាក់ដល់សិក្ខាកាមថា "ជំងឺផ្តាសាយបក្សី គឺជាជំងឺដ៏កាចសាហាវមួយ ក្នុងចំណោមជំងឺកាចសាហាវជាច្រើនទៀត ដូចនេះក្នុងករណីជំងឺឆ្លងរាតត្បាតផ្សេងទៀតផ្ទុះឡើង វិធានការជាដំបូងដែលអាជ្ញាធរមូលដ្ឋានត្រូវអនុវត្តនោះ គឺដូចករណីជំងឺផ្តាសាយបក្សីដែរ រីឯវិធានជាក់លាក់ត្រូវអនុវត្តតាមការណែនាំរបស់ក្រសួង ស្ថាប័នសាមី"។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៧នាទី | ៤. ការបង្ហាញ និងធ្វើសុពលភាព<br>អ្នកសម្របសម្រួលចែកឯកសារលំហាត់ ៩.១.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែម ទៅក្នុងឯកសារលំហាត់៩.១ នូវសកម្មភាពដែលបានបន្ថែមទាំងនោះ។ | ឯកសារលំហាត់៩.១ |

## ឯកសារលំហាត់ ៩.១ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- ឃុំ សង្កាត់ប្រើប្រាស់បណ្តាញភ្នាក់ងារសេវាសុខភាពសហគមន៍ ដើម្បីផ្សព្វផ្សាយអំពីព័ត៌មានសំខាន់ៗ ស្តីពីជំងឺផ្តាសាយបក្សីដល់ប្រជាពលរដ្ឋ
- ឃុំ សង្កាត់ត្រូវទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបណ្តាញភ្នាក់ងារសេវាសុខភាពសហគមន៍ ដើម្បីប្រមូលព័ត៌មានអំពីករណីផ្ទុះឡើងនៃជំងឺផ្តាសាយបក្សី
- រាយការណ៍ជាបន្ទាន់ទៅមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក ការិយាល័យកសិកម្មស្រុកខណ្ឌ មន្ទីរកសិកម្មខេត្តក្រុង អាជ្ញាធរស្រុកខណ្ឌ និងខេត្តក្រុង ក្នុងករណីផ្ទុះឡើងនៃជំងឺផ្តាសាយបក្សី
- ដោយសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ចាត់វិធានការទប់ស្កាត់ការឆ្លងរាលដាលជាបន្ទាន់ នៅតំបន់ផ្ទុះជំងឺផ្តាសាយបក្សី
- ជួយបញ្ជូនអ្នកជំងឺទៅកាន់មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក។



ផ្តាសាយបក្សី
ជំងឺផ្តាសាយបក្សី អាចឆ្លងទៅមនុស្ស តាមរយៈមាន់-ទា ដែលឈឺ ឬងាប់
សូមណែនាំកូន លោកអ្នកកុំអោយ ប៉ះពាល់មាន់-ទា ដែលឈឺ ឬងាប់
ចំពោះព័ត៌មាន បន្ថែមសូមទាក់ទង ក្រសួងសុខាភិបាល តាមទូរស័ព្ទលេខ ០១២-៤៨៨-៩៨១ ០១២-៨៣៦-៨៦៨
គ្រោះថ្នាក់!
មាន់-ទាដែលឈឺ ឬ ងាប់ មិនមែនជារបស់សម្រាប់លេងទេ
Australian Government
AusAID



សូមលាងដៃ
អោយបានញឹកញាប់
ជាមួយសាប៊ូ ឬ ផេះ
មុនពេលទទួលទានអាហារ
ក្រោយពេលបន្ទោបង់
ដៃស្អាត =
សុខភាពល្អ
ក្រោយពេលក្អក ឬ កណ្តាស
ក្រោយពេលប៉ះពាល់ មាន់-ទា
ចំពោះព័ត៌មានបន្ថែម សូមទាក់ទង
ក្រសួងសុខាភិបាលតាមទូរស័ព្ទលេខ
០១២_៤៨៨_៩៨១ ឬ ០១២_៨៣៦_៨៦៨
Australian Government
AusAID

# ប្លង់មេរៀនទី១០
# ការបូកសរុបផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង :<br>• ចេះពិនិត្យឡើងវិញអំពីសកម្មភាពនានាដែលបានពិភាក្សានៅក្នុងមេរៀនកន្លងមក<br>• ចេះចាត់អាទិភាពសកម្មភាពទាំងនោះ និងកំណត់អ្នកទទួលខុសត្រូវក្នុងការរៀបចំ និងអ្នកទទួលខុសត្រូវក្នុងការអនុវត្ត<br>• ចេះដាក់បញ្ចូលសកម្មភាពដែលបានព្រមព្រៀងទៅក្នុងផែនការសកម្មភាពប្រចាំខែរបស់ខ្លួនផ្ទាល់<br>• ព្រមព្រៀងដាក់បញ្ចូលបញ្ហាសុខភាពទៅក្នុងរបៀបវារៈនៃការប្រជុំជាទៀតទាត់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ |
| រយៈពេលសរុប | ប្រហែល ១២០នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត និងឯកសារ ១០.១.សេចក្តីព្រាងផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន។ |
| វិធីសាស្ត្រ | ការបង្ហាញ និងការពិភាក្សាតាមក្រុមតូច។ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៣០នាទី | **១. ការបង្ហាញ និងពន្យល់ផែនការសកម្មភាព**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា "នៅក្នុងរយៈពេលជិតពីរថ្ងៃកន្លងទៅនេះ យើងទាំងអស់គ្នាបានពិភាក្សាអំពីបញ្ហាជាច្រើន និងបានលើកឡើងនូវផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ដើម្បីលើកកម្ពស់សេវាសុខភាពនៅក្នុងឃុំ សង្កាត់។ នៅពេលនេះ យើងធ្វើការបូកសរុបសកម្មភាពទាំងនោះឡើងវិញ"។<br><br>បន្ទាប់មកអ្នកសម្របសម្រួលចែកឯកសារ **១០.១.សេចក្តីព្រាងផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន** ហើយធ្វើសុពលភាពនៃសកម្មភាពទាំងនោះជាមួយសិក្ខាកាម។ នៅក្នុងការពិភាក្សានេះ សិក្ខាកាមអាចស្នើបញ្ចូលសកម្មភាពបន្ថែម ឬកាត់ចោលសកម្មភាពមួយចំនួនដែលយល់ថាមិនអាចអនុវត្តបាន។<br><br>បន្ទាប់ពីព្រមព្រៀងទៅលើសកម្មភាពហើយ អ្នកសម្របសម្រួលត្រូវពន្យល់អំពីរបៀបបំពេញកូឡោនទី៣ កូឡោនទី៤ និងកូឡោនទី៥ នៃឯកសារ ១០.១ ដោយមានលើកឧទាហរណ៍យកមកបញ្ជាក់ជូនដល់សិក្ខាកាម។ | ឯកសារ ១០.១ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៩០នាទី | ២. ការពិភាក្សាតាមក្រុម<br>អ្នកសម្របសម្រួលចែកសិក្ខាកាមតាមឃុំ សង្កាត់នីមួយៗ (៨នាក់) ដើម្បីពិភាក្សាអំពីផែនការសកម្មភាពរបស់ឃុំ សង្កាត់ខ្លួន។ ក្រុមនីមួយៗមានរយៈពេល៦០នាទីដើម្បីអនុវត្តការពិភាក្សាគ្នានេះ។ នៅក្នុងការពិភាក្សានេះ ក្រុមនីមួយៗក៏អាចបញ្ចូលសកម្មភាពនានាដែលខ្លួនយល់ថាសំខាន់ និងចាំបាច់។ នៅក្នុងអំឡុងពេលពិភាក្សាតាមក្រុមនេះ អ្នកសម្របសម្រួលត្រូវពិនិត្យមើលក្រុមនីមួយៗ ហើយជួយដល់ក្រុមណាដែលមិនទាន់យល់ច្បាស់។ តំណាងក្រុមនីមួយបង្ហាញលទ្ធផលក្រុមរបស់ខ្លួន ហើយបន្ទាប់មកអ្នកសម្របសម្រួល បូកសរុបដោយធ្វើការបំពេញបន្ថែម និងបំភ្លឺនូវរាល់ចំណុចទាំងឡាយដែលសិក្ខាកាមមិនទាន់យល់ច្បាស់។ | -ក្រដាសផ្ទាំងធំ ហ្វឺត និងស្កុត |

## ទម្រង់សម្រាប់ពន្យល់ ១០.១. ផែនការសកម្មភាពរបស់ឃុំ សង្កាត់......................លើបញ្ហាសុខភាព

| ល.រ | សកម្មភាព | អ្នកចាត់ចែងសកម្មភាព | អ្នកអនុវត្តសកម្មភាព | កំណត់សម្គាល់ផ្សេងៗ |
|---|---|---|---|---|
| | ស្រង់សកម្មភាពនានាដែលបានឯកភាពចូលក្នុងកូឡោននេះ។ | ឈ្មោះ តួនាទីអ្នកដែលទទួលខុសត្រូវក្នុងការរៀបចំ ឬចាត់ចែងសកម្មភាព។ | ឈ្មោះ តួនាទីអ្នកដែលទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពផ្ទាល់។ | ព័ត៌មានបន្ថែមដូចជា ពេលវេលា អ្នក ឬអង្គភាពរួមសហការ ...។ល។ |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

## ១០.១. សេចក្តីព្រាងផែនការសកម្មភាពរបស់ឃុំ សង្កាត់.......................លើបញ្ហាសុខភាព

| ល.រ | សកម្មភាព | អ្នកចាត់ចែងសកម្មភាព | អ្នកអនុវត្តសកម្មភាព | កំណត់សម្គាល់ផ្សេងៗ |
|---|---|---|---|---|
| ១ | ចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំផែនការមណ្ឌលសុខភាព ដោយមានការពិគ្រោះយោបល់ជាមួយសហគមន៍។ | | | |
| ២ | ប្រាកដថា អ្នកផ្តល់សេវានៅមណ្ឌលសុខភាពចូលរួម នៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ ឬកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ នៅជំហានទី១ និងទី៣។ | | | |
| ៣ | ចូលរួម និងគាំទ្រក្នុងការអនុវត្តសកម្មភាពសេវារបស់មណ្ឌលសុខភាព និងភ្នាក់ងារសេវាសុខភាពសហគមន៍។ | | | |
| ៤ | រាយការណ៍អំពីស្ថិតិទាក់ទងនឹងសុខភាព បញ្ហា ឬការផ្ទុះឡើងនៃជំងឺ និងសកម្មភាពសេវាសុខភាពទៅមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងអាជ្ញាធរមានសមត្ថកិច្ច។ | | | |
| ៥ | សម្របសម្រួល និងពិគ្រោះយោបល់ជាមួយសហគមន៍ស្តីពីថ្លៃបង់សេវានៅមណ្ឌលសុខភាព និងកំណត់គ្រួសារក្រីក្រសម្រាប់ករណីព្យាបាលដោយមិនបង់ថ្លៃ។ | | | |
| ៦ | ជម្រាបអំពីកាលវិភាគផ្តល់សេវាចុះមូលដ្ឋាននៃមណ្ឌលសុខភាព ដល់ប្រជាពលរដ្ឋតាមរយៈមេភូមិ និងភ្នាក់ងារសេវាសុខភាពសហគមន៍។ | | | |
| ៧ | ពិនិត្យតាមដានការបំពេញការងាររបស់មណ្ឌលសុខភាព និងភ្នាក់ងារសេវាសុខភាពសហគមន៍ ដើម្បីធានាបាននូវគុណភាពសេវាសម្រាប់ប្រជាពលរដ្ឋ។ | | | |
| ៨ | សម្របសម្រួល និងត្រៀមមធ្យោបាយក្នុងការបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក។ | | | |

| ល.រ | សកម្មភាព | អ្នកចាត់ចែងសកម្មភាព | អ្នកអនុវត្តសកម្មភាព | កំណត់សម្គាល់ផ្សេងៗ |
|---|---|---|---|---|
| ៩ | គ្រោងថវិកាឃុំ សង្កាត់ សម្រាប់វិនិយោគ និងគាំទ្រសកម្មភាពក្នុងការលើកកម្ពស់សុខភាពសហគមន៍។ | | | |
| ១០ | ដឹកនាំការប្រជុំជាទៀងទាត់របស់គណៈកម្មការមណ្ឌលសុខភាព។ | | | |
| ១១ | ជំរុញលើកទឹកចិត្តដល់ :<br>• ប្រជាពលរដ្ឋឱ្យប្រើប្រាស់សេវាមណ្ឌលសុខភាព<br>• ស្ត្រីមានផ្ទៃពោះឱ្យទៅពិនិត្យផ្ទៃពោះមុនពេលសម្រាល និងទទួលថ្នាំជាតិដែក<br>• ឪពុកម្តាយឱ្យយកកូនទៅទទួលថ្នាំបង្ការជំងឺ ជីវជាតិអា ថ្នាំទម្លាក់ព្រូនឱ្យបានគ្រប់ចំនួនតាមការកំណត់<br>• ម្តាយទារកធ្វើការបំបៅកូនដោយទឹកដោះម្តាយ<br>• ប្រជាពលរដ្ឋឱ្យប្រើប្រាស់តែអំបិលអ៊ីយ៉ូដ<br>• ប្រជាពលរដ្ឋ ជាពិសេសកុមារ ឱ្យអនុវត្តអនាម័យក្នុងការហូបចុក និងរស់នៅ<br>• ប្រជាពលរដ្ឋឱ្យប្រើប្រាស់មុង<br>• ប្រជាពលរដ្ឋដែលមានផ្ទុកមេរោគអេដស៍ឱ្យទទួលបានថ្នាំព្យាបាល និងពន្យារជីវិត<br>• ប្រជាពលរដ្ឋ និងអ្នកត្រៀមរៀបអាពាហ៍ពិពាហ៍ឱ្យធ្វើតេស្តឈាម ដើម្បីរកមេរោគអេដស៍។ | | | |
| ១២ | កត់ត្រា កែសម្រួល និងរាយការណ៍ជាប្រចាំនូវ :<br>• ចំនួនស្ត្រីដែលមានអាយុពី១៥ទៅ៤៩ឆ្នាំ សម្រាប់កម្មវិធីចាក់ថ្នាំបង្ការជំងឺតេតាណូស<br>• ស្ត្រីមានផ្ទៃពោះ សម្រាប់សកម្មភាពចុះតាមដាន<br>• ចំនួនទារកដែលទើបនឹងកើត | | | |

| ល.រ | សកម្មភាព | អ្នកចាត់ចែងសកម្មភាព | អ្នកអនុវត្តសកម្មភាព | កំណត់សម្គាល់ផ្សេងៗ |
|---|---|---|---|---|
| ១៣ | សម្របសម្រួល និងរៀបចំឱ្យមានការផ្សព្វផ្សាយ អំពី :<br>• អត្ថប្រយោជន៍នៃការបំបៅកូនដោយទឹកដោះម្តាយ<br>• សារៈសំខាន់នៃការប្រើប្រាស់អំបិលអ៊ីយ៉ូដ<br>• សារៈសំខាន់នៃការរស់នៅប្រកបដោយអនាម័យ<br>• ព័ត៌មានសំខាន់ៗនៃមេរោគអេដស៍ ឬជំងឺអេដស៍ និងភាពមិនរើសអើងចំពោះអ្នកផ្ទុកមេរោគអេដស៍ និងអ្នកកើតជំងឺអេដស៍<br>• ព័ត៌មានសំខាន់ៗនៃជំងឺគ្រុនផ្តាសាយបក្សី | | | |
| ១៤ | សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចាត់វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺឆ្លងនានា ដូចជាជំងឺគ្រុនផ្តាសាយបក្សីជាដើម ។ | | | |